ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី២ ឆ្នាំ២០២២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ




ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

www.ecosocc.gov.kh

info@ecosocc.kh

(855) 012 915 577 (855) 012 912 009

## ប្រសាសន៍ពេជ្របិតាស្ថាបនិកសន្តិភាពកម្ពុជា

« ... កុំចាំផ្ទុះសង្គ្រាម ទើបស្រែករកសន្តិភាព ត្រូវនាំគ្នាការពារ
សន្តិភាព ដែលយើងរកបានដោយលំបាកណាស់ ! »

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
ក្រុងព្រះសីហនុ ថ្ងៃទី ១៦ មេសា ២០២២

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- យឹម ណុលសន

និពន្ធនាយក

- អ៊ីវ ចុង

ការិយាល័យនិពន្ធ

- នរ៉ាណាប្ញទ្ធិ អានន្ទដាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

អ្នកចាត់ចែងផលិត

- ប៉ិច សុខា
- អ៊ិន តុលា

អ្នកចែកផ្សាយ

- អៀង វដ្ឋា
- សេក វុទ្ធី

ការីកុំព្យូទ័រ

- អេង រត្នមុនី
- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**


I- វាចារណកថា វិបត្តិនៅអ៊ុយក្រែន បានបង្ហាញអំពីនយោបាយ ការបរទេសកម្ពុជា ជារដ្ឋប្រជាធិបតេយ្យសេរីដូចលោកខាងលិច ១

II- បទអត្ថាធិប្បាយ បញ្ហាសង្គមធម៌ ២-៦

III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា ៧

IV- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ ៨-១៦

V- បទវិភាគ៖
- តម្លៃអគ្គិសនីជប៉ុនខ្ពស់ ដោយសារសង្គ្រាម រុស្ស៊ី-អ៊ុយក្រែន ១៧-១៩

VI- នាទីសិក្សា-ស្រាវជ្រាវ
- វដ្តជីវិត និងសារសំខាន់ នៃត្រីប្រាធំ នៅក្នុងប្រព័ន្ធជលផលទឹកសាបកម្ពុជា ២០-៣០

VII- នាទីវប្បធម៌
១- ពន្យល់ពាក្យ កសិណ ៣១
២- ស្វែងយល់ពីប្រវត្តិសង្គមមនុស្ស ៣២-៣៣

VIII- នាទីកំណាព្យ
- ឃាតកតតពូជ (កាកគតិ) ២៨-២៩
- មេអំបៅនិងដង្កូវ (បទកាកគតិ) ៣០-៣៣

IX- នាទីកំសាន្ត
- ល្បើកទន្សាយនិងខ្យង ៣៤

# វិបត្តិនៅអ៊ុយក្រែន បានបង្ហាញអំពីនយោបាយការបរទេសកម្ពុជា ជារដ្ឋប្រជាធិបតេយ្យសេរីដូចលោកខាងលិច

*ដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា*

កម្ពុជា បើនិយាយអំពីទង្វើនៃក្រុមប្រឆាំង ឬក្រុមដែលមាននិន្នាការប្រឆាំងនឹងរាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** ពួកគេតែងប្រកាសក្តែងៗមិនចេះនឿយហត់ដោយចាត់ទុកនយោបាយការបទេសកម្ពុជា ថាជារដ្ឋគ្មានប្រជាធិបតេយ្យ កុម្មុនីស្តផ្តាច់ការ ជាអាយ៉ង់នៃប្រទេសវៀតណាម ចិន និងរុស្ស៊ីជាដើម។

ជាក់ស្តែងថ្មីៗនេះបន្ទាប់ពីការផ្ទុះវិបត្តិនៅអ៊ុយក្រែន ភ្លាមៗកាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២មកនេះ ជាកាលៈទេសៈដែលពិភពលោកហាក់បែងចែកនូវមនោគមវិជ្ជាដាច់ពីគ្នារវាងលោកខាងលិចនិងលោកខាងកើត នោះយើងឃើញក្រុមប្រឆាំងឬក្រុមដែលមាននិន្នាការប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជាបានចេញមកវិភាគយ៉ាងទ្រហឹងអឹងកងគួរឱ្យអស់សំណើចថា រាជរដ្ឋាភិបាលកម្ពុជានឹងប្រកាន់នូវគោលជំហរនយោបាយ ដើរតាមខ្សែញាក់របស់ចៅហ្វាយនាយខ្លួន ដូចជាវៀតណាម ចិន និងរុស្ស៊ី ដោយគោងកន្ទុយក្បិននៃប្រទេសទាំងនេះនៅឯក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជាក់ជាពុំខាន!។

តែផ្ទុយស្រឡះ! ចំពោះវិបត្តិនៅអ៊ុយក្រែននេះ នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី២ ខែមីនា ឆ្នាំ២០២២មកនេះ គឺកម្ពុជាជារដ្ឋមួយក្នុងចំណោមរដ្ឋចំនួន១៤១ ដែលបានបោះឆ្នោតគាំទ្រអធិបតេយ្យរបស់អ៊ុយក្រែននិងបានអំពាវនាវឱ្យរុស្ស៊ីបញ្ចប់នូវប្រតិបត្តិការយោធារបស់ខ្លួននៅអ៊ុយក្រែន។ មិនត្រឹមតែប៉ុណ្ណោះ កម្ពុជាក៏ជាប្រទេសដែលយល់ព្រមឱ្យគេកត់ត្រាចូលរួមផ្តួចផ្តើមគំនិតនូវសេចក្តីព្រាងនៃការសម្រេចចិត្ត Co-Sponsers ក្នុងចំណោមប្រទេសចំនួន៩៥ ដែលបានសហការផ្តួចផ្តើមនៃដំណោះស្រាយទាំងនេះទៀតផង។

ទន្ទឹមនឹងនេះទៀត មហាសន្និបាតអង្គការសហប្រជាជាតិស្តីពី «ដំណោះស្រាយលើវិបត្តិជនស៊ីវិលអ៊ុយក្រែន» ដែលជាកិច្ចប្រជុំពិសេសបន្ទាន់លើកទី១១ របស់មហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២៤ខែមីនាឆ្នាំ២០២២មកនេះកម្ពុជាគឺជាប្រទេសស្ថិតក្នុងចំនួន១៤០នៃប្រទេសជាសមាជិកចំនួន១៩៣ ដែលបានបោះឆ្នោតគាំទ្រថែមទៀតផង ខណៈមានប្រទេសរុស្ស៊ី បេឡារុស កូរ៉េខាងជើង និងស៊ីរី ដែលបានបោះឆ្នោតប្រឆាំង ហើយប្រទេសចំនួន៣៨ ដែលក្នុងនោះរួមមាន ចិន ឥណ្ឌា ឡាវ និងវៀតណាម ជាដើមបានបន្តបោះឆ្នោតអនុប្បវាទ។

ក្រោយពីការបោះឆ្នោតនៃនយោបាយការទូតដ៏ច្បាស់លាស់របស់កម្ពុជានៅអង្គការសហប្រជាជាតិ ជាបន្តបន្ទាប់មកនេះ កម្ពុជាត្រូវបានបណ្តារដ្ឋជាសមាជិក UN និងមហាជនទូទៅបានសម្តែងនូវការសាទរ ដូចជាស្ថានទូតបារាំង និងសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជាជាដើម បានចេញសារថ្លែងអំណរគុណនិងកោតសរសើរដល់ជំហរដ៏រឹងមាំនិងច្បាស់លាស់របស់កម្ពុជា។ស្ថិតក្នុងនយោបាយដ៏ច្បាស់លាស់នេះសម្តេចតេជោ **ហ៊ុន សែន** បានថ្លែងគូសបញ្ជាក់កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ យ៉ាងច្បាស់ថា " កម្ពុជាប្រកាន់យកជំហរបោះឆ្នោតប្រឆាំងការឈ្លានពានរបស់ប្រទេសមួយទៅលើប្រទេសមួយទៀត ព្រោះបន្ទាត់នយោបាយការបរទេសកម្ពុជាអត់អនុប្បវាទទេ ហើយកម្ពុជាមិនគាំទ្រការឈ្លានពានណាមួយពីប្រទេសមួយទៅកាន់ប្រទេសមួយទៀតទេ គឺអត់ទេ! អាហ្នឹងជាគោលជំហរដាច់ណាត់របស់កម្ពុជា»។

ស្ថិតក្នុងបរិការនេះកម្ពុជាក្នុងនាមជារដ្ឋនៃសមាជិកអង្គការសហប្រជាជាតិត្រូវតែគោរពអធិបតេយ្យភាព បូរណភាពទឹកដី និងឯករាជ្យភាពនយោបាយរបស់ប្រទេសសមាជិកផ្សេងទៀត។ ដូច្នេះចំពោះគោលជំហរនយោបាយការទូតដ៏ច្បាស់លាស់របស់កម្ពុជានេះ ជាការបង្ហាញអំពីនយោបាយការបរទេសកម្ពុជា ជារដ្ឋប្រជាធិបតេយ្យសេរីដូចលោកខាងលិច៕

# បញ្ហាសង្គមធម៌

ពាក្យថា **សង្គមធម៌** មកពីពាក្យ « សង្គម+ធម៌ »។ សង្គមធម៌ជាធម៌ទាំងឡាយដែលទ្រទ្រង់ការរស់នៅរបស់មនុស្ស ហើយនិងបណ្តុះសេចក្តីសុខសប្បាយរបស់មនុស្សជាតិ តាមគ្រឿងសម្ភារៈ ប្រដាប់ប្រើប្រាស់ វិធីបច្ចេកទេសបង្កើតផលិតផល ឬតាមវិធីរៀបចំសង្គមមនុស្ស ដូចជាសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ ច្បាប់ ឬតាមស្ថាប័នផ្សេងៗ។

មែកធាងនៃសង្គមធម៌ :

ប្រដាប់រស់នៅ

ក. សង្គមសំភារៈ

- ប្រដាប់រស់នៅ
- ប្រដាប់តិចនិច
- មុខរបរវិជ្ជាជីវៈ

ខ. សង្គមវិធី

- សង្គមកិច្ច
- នយោបាយ
- ច្បាប់

គ. សង្គមនិម្មាបនកម្ម

- ស្ទូលសង្គម
- វណ្ណៈសង្គម
- អង្គការសង្គម

គេនិយមបែងចែកសង្គមធម៌ជាបីគឺ ៖

**ក. សង្គមសំភារៈ** ដើម្បីអោយមនុស្សក្នុងសង្គមរស់បានសុខ សង្គមត្រូវរៀបចំឱ្យមាន :

*ប្រដាប់រស់នៅ ដូចជា លំនៅឋាន គ្រឿងប្រដាប់ប្រើប្រាស់ គ្រឿងប្រដាប់ គ្រឿងឧបភោគ បរិភោគ ឱសថ គ្រឿងយន្ត និងឧបករណ៍ផ្សេងៗសម្រាប់ប្រើក្នុងរោងជាង រោងចក្រ សហគ្រាស ការដ្ឋាន...។ គ្រឿងប្រដាប់ ឬឧបករណ៍របស់បុព្វបុរសខ្មែរបុរាណមាន :

- គ្រឿងអាវុធ ៖ កាំបិត ពូថៅ ដាវ លំពែង ...
- ឧបករណ៍ភ្លេង ៖ ស្គរ ទ្រ សាយដៀវ ចាប៉ី ខ្លុយ សាឡៃ ...
- ឧបករណ៍នេសាទ ៖ ផ្លែសន្ទូច ចង្រប់ ស្ន ឈ្នាង អង្រុត ទ្រូ លប លាន់...
- នាវា ៖ សំពៅ សំប៉ាន ទូកផ្កាចា ទូកថ្ងៃ ទូកង ទូកចែវ ទូកប៉ុកចាយ...
- ឧបករណ៍តម្បាញ ៖ កី ត្រល់ រហាត់ ល័ក...
- កំលាំងអូសទាញ ៖ គោ ក្របី សេះ ដំរី
- លំនៅឋាន ៖ ផ្ទះរោងដោល ផ្ទះប៉ិត ផ្ទះកន្តាំង
- រទេះ ៖ រទេះក្រង់ រទេះគោ រទេះក្របី រទេះលាត រទេះសាលី រទេះសេះ ...
- កន្ទេល ៖ កន្ទេលផ្តៅ កន្ទេលស្លឹកត្នោត កន្ទេលកញ្ចូត កន្ទេលកក់...
- ភាជន៍ ៖ ឆ្នាំង ចាន ពាង ក្អម ថាស ថូ ផ្តិល ជើង កោដ្ឋ...

- ត្បាល់ ៖ ត្បាល់កិន ត្បាល់បុក ត្បាល់គឿង រឺត្បាល់ជាន់...។

*ប្រដាប់តិចនិច ដូចជា ឱសថព្យាលរោគគ្រប់ជំពូក ឧបករណ៍ធ្វើផ្ទះ ធ្វើនាវា...។ គ្រឿងប្រដាប់តិចនិចខ្មែរបុរាណមាន :

- ប្រដាប់រំលីងថ្ម ដែកភ្លើង ព្រួញជំរឆក់ ស្នាយន្ត ដែកចារ ម្ទុល ត្រា ពុម្ព
- ប្រដាប់កសិកម្ម ៖ ស្នាច ថ្លឹង រហាត់ទឹក នង្គ័ល រនាស់
- ប្រដាប់សំណង់ ៖ ដឹង ដែកខួង ដែកខៃ ដែកឆាប ដែកឈូស អង្រូស ពន្លាក

*មុខរបរវិជ្ជាជីវៈ គឺជាការងារផ្សេងៗសម្រាប់មនុស្សក្នុងសង្គមជាតិ ទៅតាមសមត្ថភាពរបស់ខ្លួន ដើម្បីរស់នៅតាមលទ្ធភាពរៀងៗខ្លួន។

មុខរបរវិជ្ជាជីវៈរបស់បុព្វជនខ្មែរបុរាណមាន :

- កសិករ ៖ ធ្វើស្រែបណ្ដោញទឹក ធ្វើស្រែអតិផល ដាំមន ចិញ្ចឹមដង្កូវនាងធ្វើសូត្រ ដាំកប្បាស បេះក្រវាញ រកឃ្មុំ រកខ្លឹមចន្ទន៍ រកជ័រ រកក្លុកដំរី រកកុយរមាស...
- ឈ្មួញ ៖ លក់មាសប្រាក់ លក់ស្រូវអង្ករ លក់កំណាត់សំពត់ផ្សេងៗ...
- អ្នកត្បាញ ៖ ក្រមាអំបោះ ក្រមាសូត្រ សំពត់ផាឱប សារុងអំបោះ សារុងសូត្រសំពត់ចរបាប់ សំពត់ហូល សំពត់អន្លូញ...
- ជាងទង ៖ ធ្វើគ្រឿងអលង្ការគ្រប់ប្រភេទអំពីមាស ប្រាក់ ពេជ្រ
- ជាងកាត់ដេរ ជាងប៉ាក់ អ្នកនេសាទ ព្រានប្រមាញ់ អ្នកធ្វើស្រែអំបិល អ្នករបាំ
- អ្នកបិតស្រា ៖ បិតស្រាទឹកឃ្មុំ ស្រាអង្ករ ស្រាក្រចាប់ ស្រាផេងស៊ី(ជាវតាខ្វាន់ ហៅតាមឈ្មោះឈើម៉្យាង)
- ជាងឈើ ៖ ធ្វើតុ ទូ គ្រែ រនាស់ នង្គ័ល នាវាតូច ធំ
- ជាងដែក ៖ ធ្វើកាំបិត ពូថៅ ដែកខួង ពន្លាកគ្រប់ប្រភេទ អាវុធយុទ្ធភ័ណ្ឌ...
- មន្ត្រីរាជការ ៖ សាស្ត្រាចារ្យ គ្រូបង្រៀន គ្រូពេទ្យ កងទ័ព ឆ្មាំ ...
- សិប្បករ ៖ ផលិតភាជន៍ប្រាក់ មាស លង្ហិន សំរិទ្ធិ ផលិតផង្ក គ្បឿង

**ខ. សង្គមវិធី** គឺជារបបសង្គម មានមុខងារសំខាន់ណាស់ក្នុងការគូសបញ្ជាក់លក្ខណៈរបស់ប្រជាជាតិនីមួយៗ។ របបសង្គមនីមួយៗមានធាតុសំខាន់បីគឺ សង្គមកិច្ច សេដ្ឋកិច្ច និង នយោបាយ។

*សង្គមកិច្ច គឺសកម្មភាពទាំងឡាយណា ដែលមានគោលដៅបំរើផលប្រយោជន៍រួមរបស់សង្គម។ ការចែកដីធ្លី ការលើកផ្លូវ ជីកប្រឡាយ ការសង់ស្ពាន សាលារៀន មន្ទីរពេទ្យ ការជួយសង្គ្រោះជនរងគ្រោះដោយសង្គ្រាមឬដោយមហាភ័យធម្មជាតិ ការបង្ក្រាបល្បែងស៊ីសង ការចាប់ជនទុច្ចរិត...។ ទាំងនេះសុទ្ធតែជាកិច្ចការសម្រាប់សម្រាលទុក្ខវេទនា កាត់បន្ថយភាពក្រីក្រ និងផ្ដល់សេចក្ដីសុខស្រួលដល់សង្គមនេះឯង។

ដូនតាខ្មែរពីបុរាណកាល បានយល់ដឹងច្បាស់ណាស់នូវសារៈសំខាន់នៃសង្គមកិច្ច ។ ឯកសារប្រវត្តិសាស្ត្រសុទ្ធតែបានបង្ហាញថា ខ្មែរចេះជីកស្រះ ជីកព្រែក ជីកបារាយណ៍ លើកទំនប់ លើកផ្លូវថ្នល់ សង់ស្ពាន សង់សាលាសំណាក់ សង់មន្ទីរពេទ្យ ។ ដោយហេតុនេះហើយ បានជាខ្មែរមានប្រពៃណីចេះជួយគ្នា សង្គ្រោះគ្នាទៅវិញទៅមក។ សព្វថ្ងៃនេះខ្មែរតែងតែធ្វើស្រែយកដៃគ្នា ជួយគ្នាក្នុងកិច្ចការផ្សេងៗ មានសង់ផ្ទះ បុណ្យផ្កា បុណ្យខ្មោចជាដើម។

សង្គមជាតិនឹងអាចមានជំហររឹងប៉ឹង និងមានអាយុកាលយឺនយូរស្ថិតស្ថេរទៅបាន លុះណាតែរាស្ត្រមានកំរិតជីវភាពខ្ពស់ គឺត្រូវតែទទួលការអប់រំ មានលំនៅឋាន មានសម្លៀកបំពាក់ មានការងារធ្វើ មានការធានារ៉ាប់រងពីរដ្ឋខាងវិជ្ជាជីវៈ មានសន្តិសុខខាងសង្គមកិច្ច...និងគ្មានអំពើអយុត្តិធម៌ក្នុងសង្គម។

*សេដ្ឋកិច្ចគឺសកម្មភាពទាំងឡាយណាដែលដើរឆ្ពោះទៅរកការបង្កើតការប្រើប្រាស់ការប្តូរនិងការបែង

ចែកផល សម្រាប់តម្រូវការរបស់សង្គមមនុស្ស។

ជាយូរលង់ណាស់មកហើយ សេដ្ឋកិច្ចខ្មែរមានមូលដ្ឋានស្ថិតនៅលើកសិកម្ម ។ ខ្មែរចេះធ្វើស្រែ តាំងពីសម័យបុព្វប្រវត្តិសាស្ត្រមកម្ល៉េះ។ គេបានរកឃើញនៅស្ថានីយសំរោងសែន អន្លង់ផ្ដៅ និងម្លូព្រៃ នូវកណ្ដៀវធ្វើអំពីថ្មរំលីង អំពីឆ្អឹងសត្វ និងអំពីលង្ហិន។ នៅសម័យមុនអង្គរ កសិកម្មខ្មែរមានការរីកលូតលាស់ណាស់ទៅហើយ ។ ចូលក្នុងសម័យអង្គរ កសិកម្មរឹតតែមានការលូតលាស់ជាងពេលណាៗទាំងអស់ ព្រោះពេលនោះ ខ្មែរមានបំណិនប្រសប់ក្នុងនយោបាយទឹក ដូចជាធ្វើស្រែមិនពឹងទៅលើមេឃទេ គេចេះជីកបារាយណ៍ធំៗសម្រាប់ស្ដុកទឹក ហើយអាចបង្កបង្កើនផលដល់ទៅបីដងក្នុងមួយឆ្នាំ។ នៅសម័យក្រោយអង្គរ ដំណាំស្រូវក៏នៅតែជាមូលដ្ឋាននៃសេដ្ឋកិច្ចខ្មែរ។នៅសតវត្សតី១៩ជនជាតិចិនបាននាំដើមម្រេចមកដាំនៅតំបន់កំពត...ដល់ក្រោយសង្គ្រាមលោកលើកទី១ បារាំងបាននាំកៅស៊ូយកមកដាំនៅតំបន់ដីក្រហមកំពង់ចាម ក្រចេះ។

កំពង់ផែធំនៅអូរកែវសម័យអាណាចក្រភ្នំ បានបង្ហាញថា នៅពេលនោះ ពាណិជ្ជកម្មក៏មាន ការលូតលាស់ណាស់ដែរ ព្រោះខ្មែរមិនគ្រាន់តែបានទាក់ទងជាមួយឥណ្ឌា ជ្វា ប៉ុណ្ណោះទេ តែរហូតដល់ចក្រភពរ៉ូម៉ាំង និងពិភពអឺរ៉ង់ថែមទៀតផង។ នៅសម័យអង្គររបរជំនួញ នៅតែមានលក្ខណៈសកម្មដដែល ហើយក្រៅពីនេះខ្មែរបានប្រកបរបរនេសាទត្រី ជាពិសេសនេសាទត្រីនៅបឹងទន្លេសាប។

និយាយរួម ដូនតាខ្មែរយើងបានស្គាល់ច្បាស់លាស់ណាស់ពីសារៈសំខាន់នៃសេដ្ឋកិច្ច ក្នុងការរស់នៅជាសង្គម ។

*នយោបាយ គឺជាសកម្មភាពក្នុងការដឹកនាំសង្គមមនុស្សឱ្យដើរឆ្ពោះទៅរកគោលដៅណាមួយ។ អ្នកនយោបាយ ដែលកាន់កាប់វាសនារបស់ប្រទេសជាតិនីមួយៗ មានកាតព្វកិច្ចត្រូវតែរិះរកឧបាយយ៉ាងណាឱ្យប្រទេសជាតិនោះបានរស់រានមានជីវិតយូរអង្វែងតទៅព្រមទាំងបានប្រកបដោយសេចក្ដីសុខចម្រើនគ្រប់វិស័យទៀតផង ។ ជនជាតិមននិងជនជាតិចាម ដែលបណ្ដោយឱ្យធ្លាក់ខ្លួនក្នុងឋានៈជាអ្នកឥតមានរដ្ឋ ឥតមានទឹកដីផ្ទាល់ខ្លួនបង្ហាញឱ្យឃើញថាខ្វះបំណិនប្រសប់ក្នុងរឿងនយោបាយ។ឯជនជាតិខ្មែរយើងក្នុងសម័យមុនៗដែលបានបណ្ដោយឱ្យបែកបាក់សាមគ្គី ជាហេតុនាំឱ្យបាត់បង់ទឹកដី ហើយរិះៗតែរលាយជាតិ អស់នៅសតវត្សទី១៨-១៩ បង្ហាញថា មានការប្រមាទច្រើនក្នុងរឿងនយោបាយនេះដែរ។

រដ្ឋខ្មែរមានរូបរាងច្បាស់លាស់នៅដើមគ្រឹស្តសករាជនៅពេលព្រាហ្មណ៍ហ៊ុនទៀនមកដល់ នាងលីវយីបានលើកទ័ពទៅតទល់នឹងអ្នកចំណូលថ្មី ។ ត្រង់នេះសឱ្យឃើញថា នៅសម័យនោះសង្គមខ្មែរ មាន ការរៀបចំយ៉ាងម៉ត់ចត់ទៅហើយ ឬក៏ថាខ្មែរមានរដ្ឋរួចហើយក៏ថាបាន ព្រោះមានធាតុសំខាន់ៗដែលផ្គុំផ្សំជារដ្ឋ គឺទឹកដីមនុស្ស របបគ្រប់គ្រង និងអធិបតេយ្យ មានសព្វអស់ទៅហើយ។

សរុបសេចក្ដីមក សង្គមកិច្ចក្ដី សេដ្ឋកិច្ចក្ដី នយោបាយក្ដី មានមុខងារសំខាន់ណាស់ ក្នុងការបម្រើប្រយោជន៍សង្គម ហើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នាថែមទៀតផង។ យ៉ាងណាមិញ បើអ្នកដឹកនាំមិនវាងវៃផ្នែកនយោបាយទេ នោះជាតិក៏មិនអាចនៅគង់វង្សបានដែរ។ បើសេដ្ឋកិច្ចទន់ខ្សោយ រាស្ត្រមុខជាគ្មានអ្វីទ្រទ្រង់អត្ថិភាពរបស់ខ្លួនទេ បើសង្គមកិច្ចគ្មានប្រសិទ្ធភាពទេ រាស្ត្រមុខជាធ្លាក់ទៅក្នុងរណ្ដៅទុក្ខ ពុំអាចស្គាល់សុភមង្គលឡើយ ។

វិធីទាំងបីមានគោលដៅតែមួយ គឺបម្រើសង្គម បម្រើផលប្រយោជន៍រាស្ត្រ រកសុភមង្គលឱ្យរាស្ត្រ។ ប៉ុន្តែនឹងសម្រេចគោលបំណងនេះបាន ទាល់តែអ្នកដឹកនាំមានចិត្តស្រឡាញ់ជាតិពិតប្រាកដ ហើយអនុវត្តវិធានការគ្រប់បែបយ៉ាងឱ្យបានសកម្មជាទីបំផុត ដើម្បីបម្រើប្រយោជន៍រាស្ត្រ ប្រយោជន៍សង្គម និង ប្រយោជន៍ប្រទេសជាតិ។

**គ. សង្គមនិម្មាបនកម្ម** គឺជាទំរង់សង្គមដែលមានលក្ខណៈសំខាន់បីគឺ ស្នូលសង្គម (គ្រួសារ) វណ្ណៈសង្គម និង អង្គការសង្គម(ស្ថាប័ន) ។

*ស្ថូលសង្គម គឺជាគ្រួសារ ហើយគ្រួសារគឺជាក្រុមមនុស្ស ដែលមានសមាសភាពដូចតទៅ : ប្តី ប្រពន្ធ កូន ហើយនិងជាយថាហេតុ សមាជិកជាញាតិសន្តាន ដែលមករស់នៅរួមក្នុងផ្ទះជាមួយគ្នា ។

គ្រួសារ គឺជាកោសិការស់នៃសង្គម។ គ្រួសារជាអ្នកធានារ៉ាប់រងបង្កបង្កើតជានិរន្តរ៍នូវពូជមនុស្ស។ គ្រួសារជាអ្នកធានារ៉ាប់រងធ្វើឱ្យបុគ្គលទាំងឡាយ ចូលរួមក្នុងជីវិតភូមិវិទ្យា និងប្រវត្តិវិទ្យានៃមនុស្សជាតិ។

នៅក្នុងគ្រួសារខ្មែរ បុរស គឺជាមេគ្រួសារដែលមានសិទ្ធិស្របច្បាប់ត្រឹមត្រូវទៅលើកិច្ចការរបស់គ្រួសារ។ ប៉ុន្តែក្នុងការប្រតិបត្តិ ស្ត្រីខ្មែរជាមេផ្ទះមានតួនាទីរក្សាប្រពៃណីខ្មែរ សម្លៀកបំពាក់ខ្មែរ សភាពសុខសាន្តក្នុងគ្រួសារ និងមានសិទ្ធិសម្រេចលើកិច្ចការផ្ទះសំបែង និងកិច្ចការផ្សេងៗទៀត ដែលទាក់ទាងនឹងអនាគតកូន និងថវិកាគ្រួសារទៀត។និយាយរួមបើសមាជិកគ្រួសារនីមួយៗគោរពប្រតិបត្តិតាមការអប់រំទូន្មានរបស់មេបាមាតាបិតាបានខ្ជាប់ខ្ជួន និងអនុវត្តភារកិច្ចរៀងៗខ្លួនបានល្អ គ្រួសារនោះនឹងបានជួបប្រទះនូវសេចក្តីសុខ និងសេចក្តីចម្រើន ហើយញុំាងឱ្យសង្គមមានការអភិវឌ្ឍ និងសុខសន្តិភាពទៀតផង។

*វណ្ណៈសង្គម សង្គមនីមួយៗតែងចែកមនុស្សជាក្រុមៗតាមជាតិ តាមការងារ តាមចំណេះវិជ្ជាជាដើម ។ ពីគ្រិស្តសតវត្សទី៥ ដល់ទី៧ មានការចែកមនុស្សក្នុងសង្គមខ្មែរជា៤វណ្ណៈគឺ ៖

- ព្រះរាជា (អាទិទេព ឬអរលោកកេស្វរៈ)
- ព្រាហ្មណ៍បុរោហិត និង ព្រះភិក្ខុសង្ឃ
- អភិជន នាម៉ឺន
- រាស្ត្រខ្ញុំ ។

នៅសម័យអង្គរ សង្គមខ្មែរមានមនុស្ស៤ក្រុម គឺ ៖

- ក្សត្រ និងព្រះរាជវង្សានុវង្ស
- ព្រាហ្មណ៍ និងបព្វជិតឯទៀត (ព្រាហ្មណ៍ លោកសង្ឃ និង តាបស)
- អ្នកជា (មន្ត្រីរាជការតូចតាច ឈ្មួញ សិល្បករ សិប្បករ និងប្រជារាស្ត្រ)
- ទាសករ និងអ្នកងារ (ខ្ញុំបំរើ)

នៅក្រោយសម័យអង្គរ សង្គមខ្មែរមិនមានចែកវណ្ណៈទេ តែចែកជាថ្នាក់ទៅវិញ ទាំងអស់ មាន៥ថ្នាក់គឺ ៖

- រាជវង្សានុវង្សជាអ្នកគ្រប់គ្រងប្រទេស ជាថ្នាក់សង្គមខ្ពស់ជាងគេ
- ពួកមន្ត្រី មានបុព្វសិទ្ធិច្រើន (មិនបង់ពន្ធ និងមិនបំពេញកិច្ចការសាធារណៈ)
- ពួកបព្វជិត ៖
    + បាគូ មានឯកសិទ្ធិជាអ្នកថែរក្សាគ្រឿងសម្រាប់រាជ្យ
    + ព្រះសង្ឃ ជាថ្នាក់សង្គមពិសេស (ចៅក្រមគ្រហស្ថពុំអាចកាត់ទោសកំហុសបាន)
    + អ្នកជា (ពូជព្រៃងារ) ជាអ្នកស្រែចំការ ឈ្មួញ អ្នកនេសាទជាដើម ។

-ខ្ញុំ មានបីប្រភេទ ៖

+ ខ្ញុំស្តេច គឺពួកឈ្លើយសង្គ្រាម ឧក្រិដ្ឋជន ឃាតក ជនក្លែងប្រាក់ ជនធានា អ្នកទោស ឧក្រិដ្ឋរត់រួច ជនដុតផ្ទះគេ និងកូនពួកខ្ញុំរបស់ស្តេច ។ ខ្ញុំប្រភេទនេះគេហៅថា អ្នកងារ ។

+ ខ្ញុំវត្ត មានឈ្មោះម្យ៉ាងទៀតហៅថា ពលព្រះ ដែលកើតមកពីម្តាយ ជាពលព្រះ ជនធ្វើឃាតព្រះសង្ឃ ជនលួចទ្រព្យគរុភណ្ឌ ដុតវត្ត សង្ឃប្រព្រឹត្តកាមគុណ សហាយស្មន់ ជនធ្វើថ្នាំ ពន្លូត កូន...។

+ខ្ញុំគេជាខ្ញុំកំដរពួកអ្នកជាឬពួកមន្ត្រី។គឺពួកជនជំពាក់បំណុលគេគ្មានប្រាក់សងវិញពួកឈ្លើយសង្គ្រាម ឬពួកអ្នកស្រុកភ្នំដែលគេចាប់យកមកដោយបង្ខំ។

អាស្រ័យដោយសង្គមមានការវិវត្ត វណ្ណៈសង្គមខ្មែរក៏ប្រែប្រួលទៅតាមនោះដែរ។ មកដល់សព្វថ្ងៃនេះ វណ្ណៈសង្គមខ្មែររលាយអស់ទៅហើយ នៅសល់តែឋានៈ ឬថ្នាក់សង្គម គឺព្រះមហាក្សត្រ និងព្រះរាជ វង្ស ព្រះសង្ឃ មន្ត្រី និងរាស្ត្រប៉ុណ្ណោះ ។

*អង្គការសង្គម គឺការតាំង ការបង្កើតជាស្ថាប័នរួមកម្លាំងគ្នាជាពួកជាក្រុម ទោះមនុស្សក្នុងសង្គមនោះមាន ឋានៈបែបណា ឋិតក្នុងវណ្ណៈណា ក៏អាចចូលរួមគ្នាបានដោយសេរី ដើម្បីសាងវឌ្ឍនភាពក្នុងសង្គមជាតិ ដូចជាការធ្វើក្រុមហ៊ុន សហករណ៍ សហគមន៍ សមាគម និងចលនាផ្សេងៗរបស់រដ្ឋក្តី របស់ឯកជនក្តី ។

ចាប់ពីសម័យនគរភ្នំមក ទើបយើងអាចដឹងនិងស្គាល់ឈ្មោះស្ថាប័នមួយចំនួន ដូចជា ៖

- ស្ថាប័នព្រះបរមរាជវាំង : ជាស្ថាប័នកំពូល ព្រោះព្រះមហាក្សត្រជាអ្នកកាន់នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ (ពីសម័យនគរភ្នំមកដល់សម័យអង្គរ)

- ស្ថាប័នកងទ័ព : ជាស្ថាប័នសំខាន់ណាស់ ។ សម័យអង្គរ ព្រះរាជាមិនគ្រាន់តែមាន ព្រះនាមជាអគ្គមេបញ្ជាការតែប៉ុណ្ណោះទេ តែព្រះអង្គជាមេទ័ព ដឹកនាំទ័ពទៅប្រយុទ្ធជាមួយខ្មាំងសត្រូវក្នុងសមរភូមិតែម្តង។ កងទ័ពសម័យនោះចែកចេញជា៤ក្រុមគឺពលថ្មើរជើងពលដំរីពលសេះនិងពលជើងទឹក។ប៉ុន្តែមកដល់សម័យក្រោយអង្គរ កងទ័ពត្រូវបែងចែកជាពីរផ្នែក គឺទ័ពជើងគោក និងទ័ពជើងទឹក។ កងទ័ពជើងគោកឋិតនៅក្រោមអំណាចដឹកនាំរបស់ឧកញ៉ាចក្រី ហើយបែងចែកជា៤ពួក គឺពួកទ័ពដំរី ពួកទ័ពសេះ ពួកទ័ពរថ ពួកទ័ពថ្មើរជើង ទាំងអស់នេះហៅថា ចតុរង្គ។ កងទ័ពជើងទឹកឋិតនៅក្រោមការដឹកនាំរបស់ឧកញ៉ាក្រឡាហោម ។

- ស្ថាប័នតុលាការ : ស្ថាប័ននេះឋិតនៅក្នុងកណ្តាប់ដៃរបស់ស្តេចទាំងស្រុង ប៉ុន្តែមានអង្គការតុលាការមួយ ទទួល បន្ទុកក្រសួងយុត្តិធម៌ (ឧកញ៉ាយមរាជ) នៅអមព្រះអង្គផង ។

- ស្ថាប័នការទូត : តាំងពីសម័យនគរភ្នំមកដល់សម័យអង្គរ ខ្មែរមានទំនាក់ទំនង ការទូតជាមួយប្រទេសជិតខាង ដូចជាប្រទេសចិន មន ឥណ្ឌា ចាម្ប៉ា... ។

- ស្ថាប័នសាសនា : ចាប់តាំងពីសម័យនគរភ្នំមកដល់សម័យអង្គរ ព្រះរាជាខ្មែរ សុទ្ធតែជាអ្នកកាន់សាសនា ៖

+ គ.ស.វទី៩ ដល់ គ.ស.វទី១១ សាសនាព្រាហ្មណ៍ គណៈសិវនិយម មានឧត្តមភាពលើគណៈឯទៀត

+ គ.ស.វទី១២ គណៈវិស្ណុនិយម ត្រូវបានព្រះបាទសុរិយាវរ្ម័នទី២ គោរពរាប់អាន យ៉ាងសម្បើម ដូចមានប្រាសាទអង្គរជាភស្តុតាង

+ចុងគ.ស.វទី១២ ដល់ដើម គ.ស.វទី១៣ ព្រះពុទ្ធសាសនាមហាយាន ត្រូវបាន ព្រះបាទជ័យវរ្ម័នទី៧លើកតម្កើងជាសាសនាសម្រាប់រដ្ឋតែម្តង ។

- ស្ថាប័នហិរញ្ញវត្ថុធនាគារ : តាំងពីសម័យនគរភ្នំ ខ្មែរមានបោះពុម្ពប្រាក់សម្រាប់ចាយវាយក្នុងស្រុក ។ គេប្រទះឃើញ ប្រាក់កាក់ខ្មែរបុរាណច្រើនបែបយ៉ាង នៅភូមិព្រៃកពោធិ៍ អង្គរបុរី ខេត្តតាកែវ និងនៅស្ថានីយកំពង់ផែអូរកែវ កម្ពុជាក្រោម ។ នៅរាជធានីអង្គរមានឃ្លាំងធំៗហៅថា « ឃ្លាំងព្រះរាជទ្រព្យ » សម្រាប់រក្សាទុកទ្រព្យសម្បត្តិមាសប្រាក់ដែលបានមកពីការទារពន្ធដារនិងពីសួយសារអាករដែលខេត្តសាមន្តឬប្រទេសចំណុះ (សាមន្តរាជ) នាំមកថ្វាយព្រះចៅចក្រពត្រាធិរាជនៅអង្គរ ។

ក្រៅពីនេះ នៅមានស្ថាប័នផ្សេងៗទៀតដូចជា ស្ថាប័នពាណិជ្ជកម្ម អប់រំ សុខាភិបាល គមនា គមន៍ រដ្ឋបាលខេត្តក្រុង ដែលសម្របសម្រួលគ្នាជាមួយស្ថាប័នខាងលើ ដើម្បីរួមកម្លាំងគ្នា បម្រើ និង អភិវឌ្ឍ ប្រទេសជាតិ ។

ដូចនេះសង្គមជនក្នុងគ្រួសារនីមួយៗក្នុងវណ្ណៈនីមួយៗនិងក្នុងស្ថាប័ននីមួយៗត្រូវមានសិទ្ធិសេរីភាព និងករណីយកិច្ចក្នុងប្រជាជាតិខ្លួន តាមលក្ខណៈច្បាប់ស្មើៗគ្នា គោរពអ្នកដឹកនាំសង្គមជាតិរួមគ្នា មានកេតនភ័ណ្ឌរួមគ្នា មានការថែរក្សាការពារជាតិ និងបូរណភាពទឹកដីរួមគ្នា មានទំនួលខុសត្រូវចំពោះសារតារជាតិជាមួយគ្នា។

# ការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា

ការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវាត្រូវបានរាជរដ្ឋាភិបាលរៀបចំចងក្រងឡើងជាអនុក្រឹត្យ សំដៅកំណត់នូវយន្តការ បែបបទ នីតិវិធី និងគ្រប់មធ្យោបាយដ៏ទៃទៀត រួមទាំងមធ្យោបាយ "ឌីជីថល"ផងក្នុងគោលបំណងការពារផលប្រយោជន៍អ្នកប្រើប្រាស់ទំនិញនិងសេវាព្រមទាំងជំរុញឱ្យការប្រកួតប្រជែងក្នុងមុខរបរជំនួញប្រព្រឹត្តទៅបានល្អប្រសើរប្រកបដោយសុច្ចរិតភាព។

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចផ្តល់លិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មដែលបានស្នើឡើងដោយអនុលោមតាមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ឬបទបញ្ញត្តិដ៏ទៃផ្សេងទៀត។ក្រសួងពាណិជ្ជ-កម្មក៏មានសមត្ថកិច្ចផងដែរ ក្នុងការវាយតម្លៃលើអនុលោមភាពនៃការផ្សាយពាណិជ្ជកម្មនិងចាត់វិធានការណ៍ចំពោះភាពមិនសុចរឹតនៃការផ្សាយពាណិជ្ជកម្មលើផលិតកម្មទំនិញនិងសេវា។ ក្នុងករណីចាំបាច់ ក្រសួងពាណិជ្ជ-កម្មក៏ត្រូវសហការជាមួយក្រសួង ស្ថាប័ន បញ្ញត្តិករ ឬនិយត្តិករពាក់ព័ន្ធ ដើម្បីគ្រប់គ្រងការផ្សាយពាណិជ្ជកម្មអោយមានប្រសិទ្ធភាពផងដែរ ។

គ្រប់ទម្រង់និងមធ្យោបាយនៃការផ្សាយពាណិជ្ជកម្ម ទោះជាមិនផ្តល់រង្វាន់ក្តី ឬផ្តល់រង្វាន់ក្តី ទោះតាមទម្រង់និងមធ្យោបាយណាក៏ដោយ មិនត្រូវមានលក្ខណៈភូតកុហក មិនពិត ពង្វាងការពិត ក្លែងបន្លំ ឬធ្វើឱ្យមានការភ័ន្តច្រឡំអំពីគុណភាព និងសុវត្ថិភាពឡើយ ។

ការផ្សាយពាណិជ្ជកម្មនិងទម្រង់នៃការផ្សាយត្រូវប្រើប្រាស់ភាសានិងអក្សរខ្មែរជាគោល។

បុគ្គលស្នើសុំឬបុគ្គលទទួលសិទ្ធិអោយចាត់ចែងផ្សាយពាណិជ្ជកម្ម ត្រូវស្នើសុំការអនុញ្ញាតជាមុនពីកម្មសិទ្ធិករឬអ្នកគ្រប់គ្រប់គ្រង។ហើយអត្ថបទផ្សាយពាណិជ្ជកម្ម ត្រូវស្នើសុំការអនុញ្ញាត្តជាមុនពីកម្មសិទ្ធិករឬអ្នកគ្រប់គ្រង មុននឹងដំណើរការផ្សាយពាណិជ្ជកម្ម។

ការផ្សាយពាណិជ្ជកម្មដែលមិនមានអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្មពីក្រសួងពាណិជ្ជកម្ម ស្ថាប័ន បញ្ញត្តិករ ឬនិយ័ត្តិករពាក់ព័ន្ធនឹងលិខិតបញ្ជាក់អនុលោមភាព ត្រូវបានហាមឃាត់ លើកលែងតែករណីដូចមានចែងក្នុងមាត្រា១៥ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា។

អាជ្ញាបណ្ណដែលចេញដោយក្រសួង ស្ថាប័ន បញ្ញត្តិករ ឬនិយត្តិករ ពាក់ព័ន្ធមានសុពលភាពមិនលើសពី ១(មួយ)ឆ្នាំ។ការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណនិងលិខិតបញ្ជាក់អនុលោមភាពត្រូវស្នើឡើងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃយ៉ាងយូរមុនពេលផុតសុពលភាព។ការស្នើសុំអាជ្ញាបណ្ណនិងលិខិតបញ្ជាក់អនុលោមភាពត្រូវបានលើកលែងចំពោះលក់បញ្ចុះថ្លៃធម្មតា ការលក់បញ្ចុះថ្លៃពិសេស ការលក់លាងឃ្លាំង ការលក់លាងឃ្លាំងដោយថ្លៃកំណត់ជាក់លាក់ បណ្ណផ្សព្វផ្សាយ ការផលិត ឬការផ្តល់សេវាទាំងឡាយណាដែលមានលក្ខណៈជាគ្រួសារឬតាមរដូវកាល ការលក់ទំនិញសេវាដែលជាស្នាដៃសិល្បនិងសិប្បកម្មផ្ទាល់ខ្លួន ការបង្ហាត់បង្រៀនជាលក្ខណឯកជន ការបង្ហាត់បង្រៀនឬអប់រំអំពីសាសនា ការបង្ហាត់បង្រៀនការតាំងបង្ហាញការលក់ផលិតផលទំនិញ សេវារបស់សមាគម អង្គការសហជីព សហគមន៍និងនីតិបុគ្គលមិនរកប្រាក់ចំណេញនានាការតាំងបងហាញការលក់ផលិតផលកសិកម្មតាមរដូវកាល សកម្មភាពដោយស្ថាប័នរដ្ឋ ។

ការផ្សាយពាណិជ្ជកម្មផលិតផលទំនិញនិងសេវា ដែលលិខីតបទដ្ឋានគតិយុត្តិបានហាមឃាត់ធ្វើពាណិជ្ជកម្មឬផ្សាយពាណិជ្ជកម្មនិងដែលធ្វើអោយប៉ះពាល់ដល់សុវត្ថិភាពសាធារណៈសុវត្ថិភាពចរាចរណ៍និងសុវត្ថិភាពសង្គម ត្រូវបានហាមឃាត់ ។

ចំពោះទោសទណ្ឌដែលមានចែងនៅក្នុងអនុក្រឹត្យនៃការផ្សាយពាណិជ្ជកម្មផលិតផលទំនិញនិងសេវា រួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ការដកហូត ឬការលុបចោលវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ឬអាជ្ញាបណ្ណ និងលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម និងការពិន័យអន្តរការណ៍ ។

*ដោយ ទេស អែតដា ក.ស.វ. - ក្រុម ២*

# IV- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ *



ការវិភាគនេះ ត្រូវបានរៀបចំឡើងក្រោយកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ដើម្បីពិភាក្សាលើស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំខាល ចត្វាស័កព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ឈុលឡា** ប្រធាន ក.ស.វ. ដែលមានសមាសភាពចូលរួម អនុប្រធានប្រចាំការ អនុប្រធានក.ស.វ. ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារក.ស.វ. ទីប្រឹក្សាបច្ចេកទេស សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែកនិងមន្ត្រីបច្ចេកទេសអគ្គលេខាធិការដ្ឋាននៃក.ស.វ. តាមរយៈប្រព័ន្ធហ្សូម (Zoom)។ ការវិភាគផ្អែកលើទិន្នន័យទទួលបានពីក្រសួងស្ថាប័នពាក់ព័ន្ធព្រមទាំងមតិយោបល់ពីអង្គប្រជុំទាំងមូល។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡ នាត្រីមាសទី១ ឆ្នាំ២០២២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង២,២% ធៀបនឹងត្រីមាសមុន និងកើនឡើង៥,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ការដឹកជញ្ជូន | +១២,១% | ប្រេងម៉ាស៊ូត | +៤៤,៤% |
| សំលៀកបំពាក់ និងស្បែកជើង | +៨,៥% | ប្រេងសាំង | +៣៧,២% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត | +៧,៦% | ឧស្ម័ន | +២៨,០% |
| ភោជនីយដ្ឋាន | +៦,២% | បន្លែ | +៨,៥% |
| ម្ហូបអាហារ | +៥,១% | ផ្លែឈើ | +៧,៩% |
| ការកម្សាន្ត និងវប្បធម៌ | +៤,៧% | ត្រីស្រស់ | +៥,២% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៤,២% | សាច់ជ្រូក | +៤,៦% |
| សុខាភិបាល | +៣,៨% | សាច់គោ | +៣,៩% |
| គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | +៣,៧% | សាច់មាន់ | +៣,៦% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។
ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

តារាង១.២. អត្រាប្តូរប្រាក់

| *បរិយាយ* | *ត្រីមាសទី១ ២០២២* | *ត្រីមាសទី៤ ២០២១* | *ត្រីមាសទី១ ២០២១* |
|---|---|---|---|
| **រ/ដុល្លារ** | ៤ ០៥០រ/$ | ៤ ០៧៤រ/$ | ៤ ០៤៥រ/$ |
| **រ/បាត** | ១២២រ/បាត | ១២២រ/បាត | ១២៩រ/បាត |
| **រ/ដុង** | ០,១៧៧រ/ដុង | ០,១៧៩រ/ដុង | ០,១៧៥រ/ដុង |
| **បាត/ដុល្លារ** | ៣៣,៣បាត/$ | ៣៣,៣បាត/$ | ៣១,៣បាត/$ |
| **ដុង/ដុល្លារ** | ២២៨៥៣ដុង/$ | ២២ ៧៧៨ដុង/$ | ២៣០៦៩ដុង/$ |
| **យ៉ន់/ដុល្លារ** | ៦,៣យ៉ន់/$ | ៦,៤យ៉ន់/$ | ៦,៦យ៉ន់/$ |

## ២. ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី១ ឆ្នាំ២០២២ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០២០ ដល់ ២០២២ (ប៊ីលានរៀល)




**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ៦ ៣៣៤,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ៥៨៣,៧ លានដុល្លារ (*មធ្យមប្រចាំខែ ១០២,៥%នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ៥ ៤៣១,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ១ ៣៥៨,១ លានដុល្លារ (*មធ្យមប្រចាំខែ ៩៨,១% នៃផែនការ*) និងចំណូលមូលធនចំនួន ៩០២,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ២២៥,៧ លានដុល្លារ (*មធ្យមប្រចាំខែ ១៤០,៣% នៃផែនការ*) (តាមតួលេខ រតនាគារជាតិ)។

➢បើធៀបនឹងត្រីមាសមុន ចំណូលថវិកាជាតិកើនឡើង ១៩,៨% និងកើនឡើង ៣,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ ២០២១។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៥ ៥៩៧,៩ ប៊ីលានរៀល កើនឡើង ៩,៤% ធៀបនឹងត្រីមាសមុននិង កើនឡើង ១០,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខរតនាគារជាតិ ចំណូលសារពើពន្ធមានចំនួន ៥ ០១១,១ ប៊ីលានរៀលកើនឡើង ៨,២% ធៀបនឹងត្រីមាសមុននិង កើនឡើង ១១,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន ៤៥១,៦ ប៊ីលានរៀលថយចុះ ១៧,៩% ធៀបនឹងត្រីមាសមុននិង ថយចុះ ២៤,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +០,៦% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (-២,៥%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -៨៧,៦% | (-៩៨,៨%) |
| | | ➢កម្រៃការគ្រប់គ្រងនិងទិដ្ឋាការនាំចេញ: -៨៦,២% | (-៦៨,៤%) |
| ➢ ចំណូលពន្ធដារ: +១៧,៨% (អគ្គនាយកដ្ឋានពន្ធដារ) | (+២៤,៤%) | ➢សម្បទានរ៉ែ: +៣,១% | (+១៥៤,៦%) |
| | | ➢អាកាសចរណ៍ស៊ីវិល: -១៩,៣% | (-១,៦%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: +៩៨,៥% | (+១៩០,៣%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ៥ ៨៣១,២ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ៤៥៧,៨ លានដុល្លារ(*មធ្យមប្រចាំខែ ៨៧% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៤ ២៦២,១ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ១ ០៦៥,៥ លានដុល្លារ(*មធ្យមប្រចាំខែ ៨៩% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១ ៥៦៩,២ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៣៩២,៣ លានដុល្លារ(តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០២០ ដល់ ២០២២ (ប៊ីលានរៀល)




➢ចំណាយថវិកាជាតិថយចុះ ៩,៩% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង ៨,៧%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ ១៧,៤% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង ១៩,៤%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី១នេះ មានអតិរេកចំនួន ៥០៣,៦ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ១២៥,៩ លានដុល្លារ (តួលេខរតនាគារជាតិ)។

## ៣. ស្ថានភាពរូបិយវត្ថុ

➡ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី១ ឆ្នាំ២០២២មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ $M_2$ មានចំនួន ១៦៣ ១៤២,៧ ប៊ីលានរៀលមានការកើនឡើង២,៨%ធៀបនឹងខែមុននិងកើនឡើង ១៣,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង** $M_2$ ក្នុងត្រីមាសនេះ ជារួមបណ្តាលមកពី ការកើនឡើងនៃរូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ ៣,៩% និងប្រាក់បញ្ញើផ្សេងទៀត ៣,៤%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុត្រីមាសទី១ ឆ្នាំ២០២២




➤ក្នុងត្រីមាសនេះ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៦,៦% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៤% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២២

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៦,៤% | ១៦,៧% | ១៦,៦% | | | | | | | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៣,៦% | ៨៣,៣% | ៨៣,៤% | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលរូបិយវត្ថុក្នុងត្រីមាសទី១ ឆ្នាំ២០២២
(ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)



តារាង៣.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំត្រីមាស

| បរិយាយ | ត្រីមាសទី១ ២០២២ | ត្រីមាសទី៤ ២០២១ | ត្រីមាសទី១ ២០២១ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ១៧១ ៥៣៣,៤<br>១៩ ២៣៨,៣ | ១៦៤ ៥២២,៤<br>១៨ ៤៥៣,៧ | ១៣៨ ៣៧៧,៥<br>១៥ ៩៨០,៣ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ប៊ីលានរៀល) | ៣៣ ៨៥១,៥ | ៣១ ៧២២,៦ | ២៩ ៤៥៧,០ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៧% | ៤,៨% | ៥,៤% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,៨% | ៤,០% | ៣,៣% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,២% | ៩,៩% | ១០,៦% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,៤% | ៨,៤% | ៨,២% |
| កម្ចីជារៀលនៅហត្ថាកសិករ | ១៧,៣% | ១៧,៧% | ១៧,១% |
| កម្ចីជារៀលនៅអម្រឹត | ១៦,២% | ១៨,០% | ១៨,០% |
| កម្ចីជារៀលនៅប្រាសាក់ | ១៦,២% | ១៦,៦% | ១៧,១% |

## ៤. ស្ថានភាព កសិកម្ម ឧស្សាហកម្ម រ៉ែ និងថាមពល សេវាកម្ម និងវប្បធម៌

➡ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន ៨៦,៣ ពាន់តោនថយចុះ៧៣,៧% ធៀបនឹងត្រីមាសមុននិងថយចុះ៥៣,១%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣ ៥៧៩,០ GWh មានការកើនឡើង៩,៤% ធៀបនឹងត្រីមាសមុននិង កើនឡើង១៧,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះៈ

- អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៤០៧,៣ GWh ( ស្មើ១១,៤%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៧៣,០% ធៀបនឹងត្រីមាសមុននិង ថយចុះ១៥,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ១ ២៣៦,៨ GWh ( ស្មើ៣៤,៦%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង៥៧,៧% ធៀបនឹងត្រីមាសមុននិង កើនឡើង៩,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គិសនីផ្គត់ផ្គង់ដោយថាមពលពន្លឺព្រះអាទិត្យ (Solar) មានចំនួន ១៧២,០ GWh ( ស្មើ៤,៨%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង១៣,៣% ធៀបនឹងត្រីមាសមុននិង កើនឡើង២៣,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន ១ ៤៩៦,៩ GWh ( ស្មើ៤១,៨%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង៩១,០% ធៀបនឹងត្រីមាសមុននិង កើនឡើង៦៩,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន ១ ៤៩៦,៩ GWh ( ស្មើ៤១,៨%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង៩១,០% ធៀបនឹងត្រីមាសមុននិងកើនឡើង៦៩,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ២៦៦,០ GWh ( ស្មើ៧,៤%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)មានការកើនឡើង៥៣៨,៧% ធៀបនឹងត្រីមាសមុនប៉ុន្តែ ថយចុះ ៣៥,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន –ត្រីមាសទី១ ២០២២* | *ចំនួន–ត្រីមាសទី៤ ២០២១* | *ចំនួន–ត្រីមាសទី១ ២០២១* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៤៨ | ៣៩ | ៤៨ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៩១៤ | ១ ៨៧៩ | ១ ៨៤៤ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | ១១៨ | | ៤១៧ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១០១ | | ៣៨៣ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១ ២០៦,១ ពាន់ម៉$^2$ មានការថយចុះ៤៧,៣% ធៀបនឹងត្រីមាសមុននិងថយចុះ៦៨,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ៥៦១,៨ លានដុល្លារមានការថយចុះ៣៩,១% ធៀបនឹងត្រីមាសមុននិង ថយចុះ៦៦,២% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *បរិយាយ* | *ពាន់ម៉$^2$ – ត្រីមាសទី១ ២០២២* | *ពាន់ម៉$^2$ –ត្រីមាសទី៤ ២០២១* | *ពាន់ម៉$^2$ –ត្រីមាសទី១ ២០២១* |
|---|---|---|---|
| ▪ លំនៅឋាន | ២៧៦,៥ | ១ ០៨៩,៥ | ១ ៩១៤,៣ |
| ▪ ឧស្សាហកម្ម | ៣៣៦,២ | ៦៣៣,៧ | ៤៥១,៦ |
| ▪ពាណិជ្ជកម្ម | ៤៦១,៨ | ១៤៤,០ | ១ ៣០៤,២ |
| ▪ ទេសចរណ៍ | ៩០,៣ | ២៨,១ | ៦២,៦ |
| ▪ផ្សេងៗ | ០,០ | ០,២ | ០,០ |
| អនុញ្ញាតសរុប | ១ ២០៦,១ | ២ ២៩០,៨ | ៣ ៧៩២,៤ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះគឺពាណិជ្ជកម្ម ៣៨,៣% និងឧស្សាហកម្ម២៧,៩%នៃផ្ទៃក្រឡាសរុប។

➢**សេវាកម្ម**

តារាង៤.៣.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| *ប្រភេទ* | *ចំនួន –ត្រីមាសទី១ ២០២២* | *ចំនួន–ត្រីមាសទី៤ ២០២១* | *ចំនួន–ត្រីមាសទី១ ២០២១* |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១ ៣៦៤ | ១ ០៤៣ | ១ ៤៩០ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១៩៧ | ១៥៣ | ១៧៥ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ១ ៧៨៤ | ១ ៧៣២ | ២ ២២២ |

## ➢ការងារ

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–ត្រីមាសទី១ ២០២២ | នាក់–ត្រីមាសទី៤ ២០២១ | នាក់–ត្រីមាសទី ១-២០២១ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៤៩៣ | ៧៤៥ | ២ ៦៩២ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ៨៤ ៥៤២ | ៤៩ ០២១ | ៤៧ ៣៨៨ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៨២ ៧១២ | ៤៨ ២៦២ | ៤៦ ៣៧២ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១ ៨៣០ | ៧៥៩ | ១ ០១៦ |

## ➢ វិនិយោគ

តារាង៤.៥.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ត្រីមាសទី១ ២០២២ | ត្រីមាសទី៤ ២០២១ | ត្រីមាសទី១ ២០២១ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២ ៥២០,៦ | ៩៩៦,៧ | ២ ២០៧,៣ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៦៦,១ | ១៧,២ | ៤៣,១ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៦១១,១ (៣០១,២) | ៨៧៣,០ (៨៧,៧) | ៨១៦,១ (២០៩,០) |
| វិស័យទេសចរណ៍ | ១២៩,០ | ០,០ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១ ៧១៤,៤ | ៤៤១,៤ | ១ ៣៤៨,២ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៤៧ | ៣៥ | ៤៩ |
| បង្កើតការងារ (ពាន់នាក់) | ៣៨,៧ | ២៧,៤ | ២៩,៤ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន ៣ ១១១,១ ពាន់តោន មានការកើនឡើង១៦,៤%ធៀបនឹងត្រីមាសមុននិងមានការកើនឡើង១២,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)

| | |
|---|---|
| កំពង់ផែភ្នំពេញ: -១៤,០% | (-២៣,៣%) |
| កំពង់ផែកំពង់សោម: +៣២,៧% | (+៣៣,៦%) |

## ➢ការចុះបញ្ជី និងចរាចរណ៍

តារាង៤.៧.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន–ត្រីមាសទី១ ២០២២ | ចំនួន–ត្រីមាសទី៤ ២០២១ | ចំនួន–ត្រីមាសទី១ ២០២១ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ១៤៩,២ | ១២៥,៦ | ១៤១,៤ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ២៦,០ | ១៦,៧ | ២៥,០ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ៨៦៩ | ៧៨២ | ៧៥៣ |

➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៣១,៩ | -២៦,២% | -១២,៩% |
| ក្នុងនោះទទួល | ៨,៦ | +៥,២% | -៥,៩% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១១១,៥ | +៧,៥% | +១២១,៩% |
| ក្នុងនោះទទួល | ៨៦,៣ | +៣,១% | +៤៩,២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២ ៤៥៧,៥ | -៧,១% | -១៦,៥% |
| ក្នុងនោះហៅចូល | ១ ០៤១,១ | -៦,២% | -២៣,៤% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៣ ៩៥០,០ | -២៩,៤% | -៥៤,៩% |
| ក្នុងនោះហៅចូល | ៣ ៨៨៩,២ | -២៩,៣% | -៥៥,២% |

➢ ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៣,៩ | +៣៣៧,៧% | +៨៤២,១% |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ១៩,៨ | +១៩៥,៩% | +៣៤២,៧% |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ២៤,២ | +៣,៩% | +២៤,១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៥,០ | +៨៣១,៤% | +១៧០,៦% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ១៨៩,៤ | +១១៧,៦% | +១៦៨,៥% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៣០,៤ | +១២៦,០% | +៤៥២,០% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ១៥៩,៤ | +១៤៥,៩% | +១២៤,៨% |
| ✓ តាមផ្លូវអាកាស | ៨៧,០ | +១៣៦,៥% | +១៥៩,៤% |
| ✓ តាមផ្លូវគោក និងទឹក | ៧២,៦ | +១៥៨,៨% | +៩៤,២% |

## ៥. ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាត្រីមាសទី១ ឆ្នាំ២០២២ មានចំនួន ២៨ ៩៩២,៧ ប៊ីលានរៀល (ស្មើនឹង ៧១៤៨,២ លានដុល្លារ) ថយចុះ៦,៧% ធៀបនឹងត្រីមាសមុន និងថយចុះ ៤,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន,

ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---:|---:|
| ប្រេងសាំង | -៧,៩% | -៤,៨% |
| ប្រេងម៉ាស៊ូត | +៩,៩% | -៦,៥% |
| ឧស្ម័ន | -៣,៥% | +១០,៩% |
| អគ្គិសនីនាំចូលដោយ EDC | +៩១,០% | +៦៩,១% |
| ដែកសំណង់ | +២៦,៩% | -២១,៩% |
| ស៊ីម៉ង់ត៍ | +៩,៩% | -៧៣,០% |
| ជីកសិកម្ម | -២៧,៤% | -២១,៣% |
| នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម | -៦,៩% | +១០៩,៣% |
| រថយន្តសរុប (ប៊ី.ល.រ) | +១,៧% | +១៨,៥% |
| រថយន្តសរុប (គ្រឿង) | -៤,២% | +៨,៤% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៣៤,០% | +៣២,២% |
| ស្រូវសាលី | +៧៣,០% | -២៣,៦% |
| អង្ករ | +១៧៦,៤% | -៧៧,៦% |
| ផ្លែឈើនិងបន្លែ | -៩១,១% | -៧៥,៣% |
| ថ្នាំកសិកម្ម | -១២,៤% | -២,៩% |
| នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -០,៣% | +១៥,៨% |

➡ **ការនាំចេញ** ត្រីមាសទី១ ឆ្នាំ២០២២ មានចំនួន **២០ ១៨៨,២** ប៊ីលានរៀល ស្មើនឹង **៥ ០៤៧,១** លានដុល្លារ សហរដ្ឋអាមេរិក (**៧០,៦%** នៃការនាំចូល)កើនឡើង២,០% ធៀបនឹងត្រីមាសមុននិង កើនឡើង៣០,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---:|---:|
| ផលិតផលឈើកែច្នៃ | +១០,៦% | -៣,៤% |
| វាយនភណ្ឌនិងស្បែកជើង | -១,០% | +២៣,៧% |
| អង្ករ | -២២,៦% | +៩,៩% |
| ផលិតផលនេសាទ | +១០៣,៥% | -១៥,៦% |
| កៅស៊ូ | -២៣,៣% | +១,៦% |

# តម្លៃអគ្គិសនី ជប៉ុន ខ្ពស់ ដោយសារសង្គ្រាម រុស្ស៊ី-អ៊ុយក្រែន

អ្នកឯកទេសថាមពលជប៉ុនលោកTakeoKikkawaបានរកឃើញថាគិតអំពីទសវត្សរ៍ឆ្នាំ1970ក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះពេលដែលការកើនឡើងនៃតម្លៃប្រេងបានធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រទេសជប៉ុនធ្លាក់ចុះជាលទ្ធផលដែលបានកត់ត្រាកំណើនអវិជ្ជមានជាលើកដំបូងចាប់តាំងពីការបញ្ចប់សង្គ្រាម លោកលើកទីពីរ។

ការលុកលុយរបស់រុស្ស៊ីមកលើអ៊ុយក្រែន - និងការដាក់ទណ្ឌកម្មជាដោយប្រទេស G7 និងសម្ព័ន្ធមិត្តលោកខាងលិចផ្សេងទៀតរួមទាំងការផ្គត់ផ្គង់ថាមពល-ជាលទ្ធផលបានធ្វើឱ្យប្រទេសជប៉ុនប្រឈមនឹងបញ្ហានៃយុទ្ធសាស្រ្តថាមពលរបស់ខ្លួន។ជប៉ុនបានដឹងថាខ្លួនស្ថិតនៅក្នុងចណុចមួយដែលមិនអាចច្រណែនបាននៃការមានផ្លូវតិចជាងប្រទេសផ្សេងៗទៀតក្នុងការកាត់បន្ថយការពឹងផ្អែកតម្រូវការថាមពលគ្រប់យ៉ាងលើរុស្ស៊ី។

ប្រទេសក្រីក្រថាមពល(ជប៉ុន)បាននាំចូល88ភាគរយនៃការផ្គត់ផ្គង់ថាមពលរបស់ខ្លួនដែលភាគច្រើនជាប្រេងឧស្ម័ននិងធ្យូងថ្ម។ជប៉ុនជាអ្នកនាំចូលឧស្ម័នធម្មជាតិរាវ(LNG)ធំទីពីររបស់ពិភពលោកបន្ទាប់ពីប្រទេសចិន។

រុស្ស៊ីមិនមែនជាអ្នកផ្គត់ផ្គង់ថាមពលធំបំផុតសម្រាប់ជប៉ុនទេនៅឆ្នាំ2021ជប៉ុនបាននាំចូល8.7ភាគរយនៃ LNG និង 3.7ភាគរយនៃប្រេងឆៅ ប៉ុន្តែការនាំចូលទាំងនេះបានជួយជំរុញសន្តិសុខថាមពលរបស់ប្រទេស។ បច្ចុប្បន្នជប៉ុនទទួល បានការនាំចូលប្រហែល 13 ភាគរយនៃការផ្គត់ផ្គង់ថាមពលធ្យូងថ្មពីប្រទេសរុស្ស៊ី។

ប្រទេសជប៉ុនក៏នាំចូលLNGពីប្រទេសអូស្ត្រាលីនិងប្រេងពីប្រទេសអាស៊ីអាគ្នេយ៍ដែលជាប្រភពថាមពលដ៏ធំបំផុតរបស់ប្រទេសជប៉ុន ដែលបង្កើតបានប្រហែល40ភាគរយនៃតម្រូវការប្រើប្រាស់ដែលភាគច្រើនទៀតត្រូវបាននាំ ចូលពីមជ្ឈិមបូព៌ា។

លោកKikkawaបាននិយាយថាស្ថានការណ៍បន្ទាន់ដែលជប៉ុនប្រឈមនឹងពេលនេះហួសពីអ្វីដែលបានកើតឡើងក្នុងឆ្នាំ ២០១១ នឹងគ្រោះមហន្តរាយ Fukushima ហេតុការណ៍ នោះបានបង្ខំឱ្យម៉ាស៊ីនរ៉េអាក់ទ័រនុយក្លេអ៊ែរ ដែលនៅពេលនោះកំពុងផ្តល់ការផ្គត់ផ្គង់អគ្គិសនីប្រហែល 30 ភាគរយរបស់ប្រទេសត្រូវបានបិទ។

អ្នកប្រើប្រាស់និងធុរកិច្ចជប៉ុនកំពុងចាប់ផ្តើមមានអារម្មណ៍ចលាចលនៅក្នុងទីផ្សារថាមពលដែលនាំមកដោយសង្គ្រាមការដាក់ទណ្ឌកម្មនិងការកើនឡើងនៃតម្រូវការថាមពលនៅពេលដែលប្រទេសនានាបានធូរស្បើយពីជំងឺរាតត្បាត  ក៏ដូចជាការផ្លាស់ប្តូរថាមពលដែលមើលឃើញថាមូលនិធិត្រូវបានបង្វែរឆ្ងាយពីការទាញយកឥន្ធនៈហ្វូស៊ីល ដើម្បីគាំទ្រដល់ថាមពលកើតឡើងវិញ (renewable energy)។

ជាមួយនឹងប្រទេសជប៉ុនប្រឈមនឹងការបោះឆ្នោតជាតិក្នុងខែកក្កដា ២០២២ នាយករដ្ឋមន្ត្រី Fumio Kishida ចង់ជៀសវាងការឡើងថ្លៃសាំង និងហានិភ័យនៃការដាច់ភ្លើង។

រដ្ឋាភិបាលរបស់លោកKishidaក៏បាននិងកំពុងផ្តល់ការឧបត្ថម្ភធនដល់អាជីវករលក់ដុំដើម្បីកាត់បន្ថយតម្លៃនៅស្ថានីយ៍បូមប្រេងខណៈពេលដែលអាជ្ញាធរកំពុងពិចារណាលើវិធានការកាន់តែធ្ងន់ធ្ងរជាងមុន-កាត់បន្ថយពន្ធប្រេងឥន្ធនៈជាបណ្តោះអាសន្ន។

តម្លៃអគ្គិសនីកើនឡើងពីមួយខែទៅមួយខែ។  Tepco ដែលជាក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់តូក្យូកំពុងបន្ថែមការគិតថ្លៃបន្ថែមជាមធ្យម 1,813 យ៉េន (14 ដុល្លារអាមេរិក) ដល់គ្រួសារក្នុងខែនេះ បន្ថែមទម្ងន់ប្រឈមនឹងការចំណាយ។

ប្រទេសជប៉ុនក៏មានក្តីសង្ឃឹមតិចតួចផងដែរក្នុងរយៈពេលវែងដោយសារតែគម្រោងថាមពលដែលមាន

ស្រាប់របស់ប្រទេសជប៉ុននៅក្នុងប្រទេសរុស្ស៊ីស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។

បន្ទាប់ពីវិបត្តិប្រេងនៅឆ្នាំ1970ប្រទេសជប៉ុនបានព្យាយាមធ្វើពិពិធកម្មប្រភពថាមពលរបស់ខ្លួនដោយការវិនិយោគនៅក្នុងគម្រោងចំនួនពីរនៅលើកោះ Sakhalin របស់រុស្ស៊ីក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។

ទំនាក់ទំនងរបស់ប្រទេសទាំងពីរបានស៊ូទ្រាំទោះបីជាទីក្រុងតូក្យូនិងមូស្គូកំពុងជាប់គាំងក្នុងជម្លោះលើអធិបតេយ្យភាពនៃកោះ Kurils ភាគខាងត្បូងដែលគ្រប់គ្រងដោយរុស្ស៊ី ដែលជាប្រជុំកោះលាតសន្ធឹងប្រវែង 1,200 គីឡូម៉ែត្រ ( 750 ម៉ាយ ) ពីប្រទេសរុស្ស៊ីទៅប្រទេសជប៉ុន ទីក្រុងតូក្យូសំដៅទៅលើវាថាជាដែនដីនៃភាគខាងជើង។

ប្រទេសជប៉ុនបាននាំចូលប្រេងឆៅដែលមានគុណភាពខ្ពស់ពីគម្រោង Sakhalin 1 ពាក់ព័ន្ធនឹងការវិនិយោគពីក្រុមហ៊ុនពាណិជ្ជកម្ម Itochu និង Marubeni និងការចូលរួមពីក្រុមហ៊ុនប្រេងយក្សជប៉ុន Inpex ។

ក្រុមហ៊ុនប្រេងដ៏ធំរបស់សហរដ្ឋអាមេរិក ExxonMobil បានប្រកាសពីការដកខ្លួនចេញពីគម្រោងនេះដើម្បីបង្ហាញពីសាមគ្គីភាពជាមួយអ៊ុយក្រែននៅថ្ងៃទី 1 ខែមីនា។

ប្រទេសជប៉ុនក៏បាននាំចូលLNGពីSakhalin2ដែលជាគម្រោងដែលពាក់ព័ន្ធនឹងក្រុមហ៊ុនពាណិជ្ជកម្មផ្សេងទៀតដូចជា Mitsubishi និង Mitsui ។ ប៉ុន្តែ នោះ ក៏ ស្ថិត ក្នុង គ្រោះថ្នាក់ ដែរ ដោយ ក្រុមហ៊ុន ប្រេង និងឧស្ម័ន ពហុជាតិ របស់ ចក្រភព អង់គ្លេស Shell បាន ប្រកាស ពី ផែនការ ដក ខ្លួន ចេញ។

លើសពីនេះ ក្រុមហ៊ុន Mitsui និង Japan Oil, Gas and Metals National Corporation បានបណ្តាក់ទុននៅក្នុងគម្រោង Arctic 2 LNG នៅតំបន់អាក់ទិករុស្ស៊ី ដែលត្រូវ បានគេរំពឹងថានឹងចាប់ផ្តើមប្រតិបត្តិការនៅឆ្នាំ 2023 និងផលិត LNG ដល់ទៅ 20 លានតោនក្នុងមួយឆ្នាំ។

ទោះជាយ៉ាងណាក៏ដោយ ធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិដែលជួយផ្តល់ហិរញ្ញ-ប្បទានដល់គម្រោង នេះ ថ្មីៗនេះបានប្រកាសថាខ្លួននឹងផ្អាកការផ្តល់ប្រាក់កម្ចីជាបណ្តោះអាសន្ន។ កាលពីថ្ងៃទី 1 ខែមេសា រដ្ឋមន្ត្រីឧស្សាហកម្ម Koichi Hagiuda បាននិយាយថា ប្រទេសជប៉ុននឹងមិនដកខ្លួនចេញពីគម្រោងទាំងបីនេះទេ។ លោកបានមានប្រសាសន៍ថា៖ «ពួកគេជាគម្រោងដ៏មាន សារៈសំខាន់ ខ្លាំង ពី ទស្សនៈសន្តិសុខថាមពល »។

លោក Kikkawa ជឿថា តាមទស្សនៈសេដ្ឋកិច្ច ជប៉ុន គួរតែរក្សាគម្រោងទាំងនេះ ព្រោះថា ប្រសិនបើជប៉ុនដកខ្លួនចេញ ចិន និង ឥណ្ឌា ប្រាកដជានឹងមានគម្រោងឈានជើងចូល"។

លោក Ken Koyama ប្រធានសេដ្ឋវិទូ និងជានាយកគ្រប់គ្រងជាន់ខ្ពស់នៅវិទ្យាស្ថានសេដ្ឋកិច្ចថាមពលប្រទេសជប៉ុនបានចង្អុលបង្ហាញឧទាហរណ៍មួយអំពីរបៀបដែលទីក្រុងតូក្យូបាត់បង់ធនធានថាមពលនៅពេលដែលវាជាប់គាំងទៅនឹងគោលការណ៍របស់ខ្លួន។“ក្រុមហ៊ុនជប៉ុនមួយបានទិញសិទ្ធិអភិវឌ្ឍន៍អណ្តូងប្រេងAzadegan [នៅអ៊ីរ៉ង់]។ ទោះបីជាយ៉ាងណាក៏ដោយ អ៊ីរ៉ង់ និងអាមេរិកបានឈ្លោះប្រកែកគ្នាលើបញ្ហាផ្សេងៗ ហើយនៅពេលដែលសហរដ្ឋអាមេរិករឹតបន្តឹងទណ្ឌកម្មប្រឆាំងនឹងអ៊ីរ៉ង់ ទីបំផុតជប៉ុនបានសម្រេចចិត្តដកខ្លួនចេញពីគម្រោងនេះ ហើយក្រុមហ៊ុនចិនដែលបានបំពេញចន្លោះទទេនោះ»។

យ៉ាងណាក៏ដោយនៅពេលដែលសង្គ្រាមកាន់តែកើនឡើងហើយជាមួយនឹងការចោទប្រកាន់ចុងក្រោយនៃកងទ័ពរុស្ស៊ីដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅអ៊ុយក្រែនជប៉ុនអាចនឹងបង្ខំចិត្តធ្វើសកម្មភាពបន្ថែមទៀត។ ទីក្រុងតូក្យូ បាននិយាយថា គោលដៅរយៈពេលវែងរបស់ខ្លួនគឺបញ្ឈប់ការនាំចូលធ្យូងថ្មពីប្រទេសរុស្ស៊ីបន្ទាប់ពីមេដឹកនាំនៃG7បាននិយាយថាប្រទេសរបស់ពួកគេនឹងហាមឃាត់ការវិនិយោគថ្មីទៅក្នុងវិស័យថាមពលរបស់រុស្ស៊ី និងពង្រីកការរឹតបន្តឹងពាណិជ្ជកម្ម រួមទាំងការផ្អាក និងហាមឃាត់ការនាំចូលធ្យូងថ្ម។

ក្នុងបរិយាកាសមិនច្បាស់លាស់បែបនេះ ជប៉ុនត្រូវចាប់ផ្តើមពឹងផ្អែកលើប្រទេសផ្សេងទៀត។ លោក Koyama បាននិយាយថា ទីក្រុងតូក្យូគួរតែពង្រឹងទំនាក់ទំនងជាមួយកាណាដា កាតា និងសហរដ្ឋអាមេរិក ដែល

មានសក្តានុពលក្នុងការបង្កើនការផ្គត់ផ្គង់ឧស្ម័នធម្មជាតិនៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ ប៉ុន្តែលោក Kikkawa បានចង្អុលបង្ហាញពីរបៀបដែលអឺរ៉ុបក៏នឹងត្រូវការការផ្គត់ផ្គង់ឧស្ម័នជំនួសផងដែរដែលបានផ្តល់ឱ្យសង្គ្រាមនៅអ៊ុយក្រែននិងការដាក់ទណ្ឌកម្មលើប្រទេសរុស្ស៊ី។អ្នកជំនាញជប៉ុនមិនសូវព្រួយបារម្ភអំពីការផ្គត់ផ្គង់ប្រេងដោយចង្អុលទៅរបៀបដែលអារ៉ាប៊ីសាអូឌីត និងប្រទេសផលិតប្រេងឈូងសមុទ្រផ្សេងទៀតអាចបង្កើនផលិតកម្ម។

លោក Kishida បាននិយាយទៅកាន់ព្រះអង្គម្ចាស់ UAE ព្រះអង្គម្ចាស់ Sheikh Mohammed bin Zayed al-Nahyan នៅថ្ងៃទី 15 ខែមីនា ហើយរដ្ឋមន្ត្រីការបរទេស Yoshimasa Hayashi បានទៅបំពេញទស្សនកិច្ចនៅប្រទេសនេះភ្លាមៗ។ ទោះជាយ៉ាងណាក៏ដោយ ការធានា LNG គឺជារឿងឈឺ ក្បាលខ្លាំងជាង។ មិនដូចប្រេងទេទុនបំរុងLNGមិនទាន់មានទេរុស្ស៊ីជាអ្នកនាំចេញឧស្ម័នធម្មជាតិដ៏ធំបំផុតរបស់ពិភពលោកហើយសមត្ថភាពផលិតនៅកន្លែងផ្សេងទៀតពិបាកនឹងបង្កើតភ្លាមៗ។

ទីផ្សារឧស្ម័ននៅអឺរ៉ុបបានស្ថិតក្នុងភាពចលាចលតាំងពីឆ្នាំមុនមកម្ល៉េះដោយសារប្រទេសរុស្ស៊ីបានពន្យឺតលំហូរនៃបំពង់បង្ហូរប្រេង ហើយតម្រូវការអាស៊ីបានកើនឡើង ដែលជំរុញឱ្យតម្លៃកើនឡើងនៅទូទាំងពិភពលោក។

ឧស្ម័នLNGរបស់ប្រទេសជប៉ុនត្រូវបានធានាជាចម្បងតាមរយៈកិច្ចសន្យារយៈពេលវែងប៉ុន្តែតម្លៃកន្លែងបានហក់ឡើងពីប្រហែល 26 ដុល្លារទៅ 85 ដុល្លារនៅពេលដែលសង្គ្រាមបានផ្ទុះឡើង ដែលក្រោយមកបានធ្លាក់ចុះមកនៅប្រហែល30ដុល្លារវិញ។ស្ថានភាពនេះបានធ្វើឱ្យមានការជជែកដេញដោលគ្នាដោយជៀសមិនរួចអំពីការ ប្រើប្រាស់ថាមពលនុយក្លេអ៊ែរនៅក្នុងប្រទេសជប៉ុន ហើយប្រសិនបើរដ្ឋាភិបាលគួរតែអនុញ្ញាតឱ្យម៉ាស៊ីនរ៉េអាក់ទ័របន្តដំណើរការឡើងវិញ នោះក៏ព្រោះតែដោយសារការកើនឡើងយ៉ាងខ្លាំងនៃថ្លៃថាមពល។

សមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យសេរីដែលកំពុងកាន់អំណាចបានស្នើឱ្យរដ្ឋាភិបាលជំរុញការអភិវឌ្ឍន៍ម៉ាស៊ីនរ៉េអាក់ទ័រម៉ូឌុលខ្នាតតូចជំនាន់ក្រោយ ( small modular reactor ) រ៉េអាក់ទ័រនុយក្លេអ៊ែរដែលផលិតអគ្គិសនីដែលមានទំហំតូចជាង និងមានសមត្ថភាពសុវត្ថិភាពជាងការរចនាមុនៗ។

យោងតាមការស្ទង់មតិរបស់កាសែត Nikkei នៅចុងខែមីនា អ្នកឆ្លើយសំណួរចំនួន 53 ភាគរយបានអំពាវនាវឱ្យប្រើប្រាស់ម៉ាស៊ីនរ៉េអាក់ទ័រនុយក្លេអ៊ែរបន្ថែមទៀតនៅក្នុងប្រទេសជប៉ុន។នេះក៏នឹងភ្ជាប់ជាមួយនឹងការសន្យារក្សាថាមពលរបស់រដ្ឋាភិបាលនិងការរំលាយកាបូនដែលជាផ្នែកនៃគោលដៅបម្រែបម្រួលអាកាសធាតុ។ ប៉ុន្តែវានឹងក្លាយជាផ្លូវវែងឆ្ងាយនៃកំណែទម្រង់ដែលនឹងមិនដោះស្រាយការខ្វះខាតនាពេលបច្ចុប្បន្ននៅក្នុងការផ្គត់ផ្គង់ថាមពលនោះទេ។

លោកKikkawaបានព្យាករណ៍ថាក្នុងពេលជាមួយគ្នានេះ ប្រទេសជប៉ុននឹងត្រូវរៀបចំខ្លួនសម្រាប់តម្លៃអគ្គិសនី"កាន់តែថ្លៃជាងមុន" ។

ដោយ នរ៉ាំណាឫទ្ធិ អានន្ទដាយ៉ាត

ប្រភព៖ SCMP, រាយការណ៍បន្ថែមដោយ Reuters និង Bloomberg

# វដ្តជីវិត និងសារសំខាន់នៃត្រីប្រាធំ នៅក្នុងប្រព័ន្ធជលផលទឹកសាបកម្ពុជា (ត)

## តារាង២. ទីតាំងយកសំណាកគំរូ កំរិតក្រពេញបន្តពូជ ខ្លាញ់ ចំណី និងទីតាំងនេសាទកូនត្រីប្រា

| ឆ្នាំ | មករា - មិនា | មេសា - មិថុនា | កក្កដា - កញ្ញា | តុលា - ធ្នូ |
|---|---|---|---|---|
| ១៩៨១ | | | ឡូត៍ដាយកូនត្រីប្រា(កណ្តាល) | ឡូត៍ដាយត្រី (កណ្តាល) |
| ១៩៨២ | ឡូត៍ដាយត្រី (កណ្តាល) | | ឡូត៍ដាយកូនត្រីប្រា(កណ្តាល និងទន្លេតូចខេត្តព្រៃវែង)) | ឡូត៍ដាយត្រី (កណ្តាល) |
| ១៩៨៣ | ឡូត៍ដាយត្រី (កណ្តាល) | ទីតាំងនេសាទឧបករណ៍នាម (ដងទន្លេសាប ខេត្តកណ្តាល) | | ឡូត៍នេសាទ២,៣,៤ (កំពង់ធំ) |
| ១៩៨៤ | ឡូត៍នេសាទ២,៣,៤ (កំពង់ធំ) | | ទីតាំងនេសាទអួនសម្រុងនៅ រាំងទិល ដីរនាត (បឹងទន្លេសាប) | ឡូត៍នេសាទ១៤ស្ទឹងជ្រៅ (កណ្តាល) |
| ១៩៨៥ | ឡូត៍នេសាទ១៤ស្ទឹងជ្រៅ (កណ្តាល) | | ទីតាំងនេសាទអួនសម្រុងនៅ រាំងទិល ដីរនាត (បឹងទន្លេសាប) | ឡូត៍នេសាទ៨ លើកដែក; ឡូត៍ ១០ ព្រែកជ្រៃ (កណ្តាល) |
| ១៩៨៦ | ឡូត៍នេសាទ៨ លើកដែក, ឡូត៍. ១០ ព្រែកជ្រៃ (កណ្តាល) | | | ទីតាំងអួនឆ្នេរខ្សាច់ (កំពង់ចាម) |
| ១៩៨៧ | ទីតាំងអួនឆ្នេរខ្សាច់ (កំពង់ចាម) | | | ឡូត៍នេសាទ២ (កំពង់ធំ) |
| ១៩៨៨ | ឡូត៍នេសាទ២ (កំពង់ធំ) | បែរចិញ្ចឹមត្រីប្រា (ផ្អកទ្រូ) | | ឡូត៍នេសាទ៤ (កំពង់ឆ្នាំង) |
| ១៩៨៩ | ឡូត៍នេសាទ៤ (កំពង់ឆ្នាំង) | បែរចិញ្ចឹមត្រីប្រា (កំបង់ឆ្នាំង) | | ឡូត៍នេសាទ១៤ (កំពង់ឆ្នាំង) |
| ១៩៩០ | ឡូត៍នេសាទ១៤ (កំពង់ឆ្នាំង) | បែរចិញ្ចឹមត្រីប្រា (ភ្នំពេញ) | | ឡូត៍នេសាទ១៨ (កំពង់ឆ្នាំង) |
| ១៩៩១ | ឡូត៍នេសាទ១៨ (កំពង់ឆ្នាំង) | បែរចិញ្ចឹមត្រីប្រា (លើកដែក) | ឡូត៍ដាយកូនត្រីប្រា (កណ្តាល) | |
| ១៩៩២ | | | ឡូត៍ដាយកូនត្រីប្រា (កណ្តាល) | |
| ១៩៩៣ | | | ឡូត៍ដាយកូនត្រីប្រា (កណ្តាល) | |
| ១៩៩៤ | ទីតាំងអួនឆ្នេរខ្សាច់ (កំពង់ចាម) | ទីតាំងអួនឆ្នេរខ្សាច់កងមាស | | |
| ១៩៩៥ | ទីតាំងអួនឆ្នេរខ្សាច់ (កំពង់ចាម) | ទីតាំងអួនឆ្នេរខ្សាច់ កោះសូទិន | | ឡូត៍ដាយត្រី (កណ្តាល) |
| ១៩៩៦ | | ទីតាំងនេសាទមងក្រឡាធំ (ខេត្តក្រចេះ និងស្ទឹងត្រែង) | | ឡូត៍ដាយត្រី (កណ្តាល) |
| ១៩៩៧ | | | ឡូត៍ដាយកូនត្រីប្រា (កណ្តាល) | ឡូត៍ដាយត្រី (កណ្តាល) |
| ១៩៩៨ | | ទីតាំងនេសាទមងក្រឡាធំ (ខេត្តក្រចេះ និងស្ទឹងត្រែង) | ឡូត៍ដាយកូនត្រីប្រា (កណ្តាល) ទីតាំងនេសាទសន្ទូចរនង (កោះ រងាវ ខេត្តក្រចេះ) | ឡូត៍ដាយត្រី (កណ្តាល) |
| ១៩៩៩ | | ទីតាំងនេសាទមងក្រឡាធំ (ខេត្តក្រចេះ និងស្ទឹងត្រែង) | ទីតាំងនេសាទសន្ទូចរនង (កោះ រងាវ ខេត្តក្រចេះ) | ឡូត៍ដាយត្រី (កណ្តាល) |
| ២០០០ | | ទីតាំងនេសាទឧបករណ៍នាម (ដងទន្លេសាប ខេត្តកណ្តាល) | ទីតាំងនេសាទសន្ទូចរនង (កោះ រងាវ ខេត្តក្រចេះ) | |




រូបភាព៥ផែនទីបង្ហាញទីតាំងចុះស្រាវជ្រាវព័ត៌មាន និងចុះយកសំណាកត្រី

(iv) ការប្រមូលផ្តុំពត៌មានដែលទទួលបានពីការស្រាវជ្រាវអង្កេតខាងលើយកមកធ្វើការវិភាគ និងពិភាក្សាយ៉ាងល្អិតល្អន់ដោយមានការពិគ្រោះយោបល់ជំនាញដើម្បីធ្វើសេចក្តីសន្និដ្ឋានជាចុងក្រោយ។

## ២.២. លទ្ធផល

ឯកសារពាក់ព័ន្ធនឹងប្រភេទត្រីប្រាជដែលស្រាវជ្រាវបាននៅតាមបណ្ណាល័យនានានៅប្រទេសថៃប្រទេសហ្វីលីពីន ជាពិសេសនៅប្រទេសបារាំង (Musee de l'Histoire Naturelle) បានបង្ហាញតែពី វត្តមានរបស់វានៅតាមមជ្ឈដ្ឋានធម្មជាតិនិងក្នុងវារីវប្បកម្មដោយសង្កត់ធ្ងន់តែទៅលើលក្ខខណ្ឌជីវសាស្ត្រមួយចំនួនដូចជាការស៊ីចំណី (ស៊ីចំណីចំរុះ) ការធន់ទ្រាំទៅនឹងបរិស្ថានប្រែប្រួល (អាចដកដង្ហើមនៅខាង លើផ្ទៃទឹកបាន) ការរីកធំធាត់ (អត្រារីកលូតលាស់ខ្ពស់និងឆាប់រហ័សអាស្រ័យទៅតាមគុណភាពនិង បរិមាណចំណីដែលអាចរកបាន) ការទម្លាក់ពង (ពងដែលទម្លាក់ជាពងស្អិតនៅពេលបានទទួលមេជីវិតរួចត្រូវតោងជាប់ទៅនឹងវត្ថុឬរុក្ខជាតិអ្វីមួយនៅក្នុងទឹក) ព្រមជាមួយការធ្វើចំណាត់ថ្នាក់ដូចខាងក្រោម៖

វជ្ជ (Kingdom) Animalia
- អំបូរ (Phylum) Chordata
  - អំបូរ-ក្រោម (Under-phylum) Vertebrata
    - សន្តាន-លើ (Super-class) Osteichthyses
      - សន្តាន (Class) Actonopterygii
        - សន្តាន-ក្រោម (Under-class)) Neopterygii
          - សន្តាន-ក្រោមបំផុត (Infra-class) Teleostei
            - លំដាប់-លើ (Super-order) Ostariophysi
              - លំដាប់ (Order) Siluriformes
                - ពូជ (Family) Pangasiidae
                  - ពួក (Genus) Pangasionodon
                    - ប្រភេទ (Species) P. hypophthamus

### ២.២.១. ការយល់ដឹងរបស់អ្នកស្រុក និងអ្នកនេសាទមូលដ្ឋានទាក់ទងនឹងត្រីប្រាធំ

-ត្រីប្រាធំទំហំចាប់ពី៤-៥គក្រឡើងទៅបានចេញពីព្រៃលិចទឹកហើយត្រូវគេនេសាទបានជាមួយប្រភេទត្រីធំផ្សេងទៀតដូចជាត្រីរាជ ត្រីគល់រាំង ត្រីត្រសក់ជាដើមនៅអំឡុងខែសីហា-កញ្ញា នៅលំហរ បឹងធំចំណុចដីរនាត-រាំងទិល។

- ត្រីប្រាធំនេះ មិនសូវប្រទះឃើញនៅក្នុងប្រព័ន្ធទឹកខេត្តស្ទឹងត្រែងទេ លើកលែងនៅអំឡុងខែធ្នូ ឆ្នាំ១៩៩៩[6] ដែលហ្វូងត្រីប្រាតូចជាង០,៥គក្រត្រូវបានគេឃើញជាតំបូងនៅព្រំប្រទល់កម្ពុជា-ឡាវ។

-ត្រីប្រាធំទាំងតូចទាំងធំត្រូវគេនេសាទបាននៅគ្រប់ដែននេសាទទឹកសាបហើយក៏មិនដែលប្រទះឃើញមានពងទេ លើកលែងតែមានម្តងនៅចុងខែកក្កដាឆ្នាំ១៩៩៨ ដែលគេនេសាទបានត្រីប្រាធំ ទម្ងន់១១គក្រមានពងព័ណខ្មៅរាគចេញពីក្នុងពោះ។ ដោយឡែកត្រីប្រាធំទំហំចាប់ពី៤-៥គក្រឡើងទៅ តែងប្រទះឃើញជារឿយៗ ថាមានពងក្នុងពោះនាខែឧសភា-មិថុនា នៅតំបន់ទឹកជួរព្រៃអញ្ចែងទន្លេមេគង្គ ក្នុងចេត្តក្រចេះជិតព្រំប្រទល់ខេត្តស្ទឹងត្រែង។

-ត្រីប្រាធំទំហំចាប់ពី៤-៥គក្រឡើងទៅ ដែលជាប់សន្ទូចនៅតំបន់ទឹកជួរព្រៃអញ្ចែងនៅពេលជំនន់ទន្លេមេគង្គហក់ឡើងតំបូងនៅខែមិថុនាមានរំអិលច្រើនជាប់ខ្លួនហើយឆ្អាបខ្លាំងណាស់។

- ត្រីប្រាធំទំហំធំធ្លាប់ត្រូវគេនេសាទបាននៅផ្នែកខាងលើស្ទឹងសែន និងស្ទឹងជីនិតនៅរដូវប្រាំង។

- កូនត្រីប្រាធំទំហំ២-៤សង្ទីម៉ែត្រ (អាយុ៧-១០ថ្ងៃ) ត្រូវគេនេសាទបានដោយដាយស្បៃមុង ចាប់ពីខេត្តក្រចេះទៅដល់ព្រំដែនកម្ពុជាវៀតណាមនៅរដូវវស្សា (១៩៨០-១៩៩៨)។

### ២.២.៣. វត្តមាននិងលក្ខណៈត្រីប្រាធំក្នុងផលនេសាទដែលចាប់បានទៅតាមតំបន់និងពេលវេលា

ការស្រាវជ្រាវអង្កេតពីវត្តមានត្រីប្រាធំ ដែលបង្ហាញខ្លួនក្នុងផលចាប់ដែលនេសាទបាននៅតាម កន្លែងផ្សេងៗ និងនៅតាមពេលវេលាខុសៗគ្នាចាប់តាំងពីឆ្នាំ១៩៨១ រហូតមកដល់ឆ្នាំ២០០០ ត្រូវបាន កត់សំគាល់ឃើញតាមលំដាប់លំដោយដូចក្នុងតារាងខាងក្រោមនេះ៖

| តំបន់ / នេសាទ / ពេលវេលា | តំបន់បឹងទន្លេសាប | ដងទន្លេសាប | ដងទន្លេមេគង្គលើ | ដងទន្លេមេគង្គក្រោម | ដងទន្លេតូច |
|---|---|---|---|---|---|
| កក្កដា - កញ្ញា | ត្រីមានទំហំធំពី ៤ - ១៦គក្រ (បរិមាណ១០% នៃផលចាប់) | | ត្រីទំហំ៤ - ៦គក្រ ១០០%ជាប់សន្ទូចនេន | កូនត្រីប្រាទំហំ២ - ៤សម (បរិមាណច្រើន | កូនត្រីប្រាទំហំ២ - ៣សម (បរិមាណតិច) |
| តុលា - ធ្នូ | ត្រីមានទំហំពី ០,២ - ៣គក្រ (បរិមាណ២០%នៃផលចាប់) | ត្រីមានទំហំធំពី ៤ - ១២ គក្រ (បរិមាណ៤០%នៃផលចាប់) | | | |
| មករា - មិនា | ត្រីមានទំហំពី ០,៣ - ២គក្រ (បរិមាណ២០%នៃផលចាប់) | ត្រីមានទំហំពី២ - -៤គក្រ (បរិមាណ៣០%នៃផលចាប់ | ត្រីមានទំហំពី ០,៤ - ៦គក្រ (បរិមាណ៤០%នៃផលចាប់) | ត្រីមានទំហំពី ០,៥ - ៨គីឡូ (បរិមាណ៤០%នៃផលចាប់) | |
| មេសា - មិថុនា | ត្រីមានទំហំពី ០,៥ - ៤គក្រ (បរិមាណ១០%នៃផលចាប់) | ត្រីមានទំហំពី១ - ៤គក្រ (បរិមាណ៣០%នៃផលចាប់ | ត្រីមានទំហំធំពី ៤ - ១១គក្រ (បរិមាណ២០%នៃផលចាប់) | ត្រីមានទំហំពី ១ - ៣គីឡូ (បរិមាណ១០%នៃផលចាប់) | |

[6] Baird, I.G., M.S. Flaherty, and P. Boumpheng, 2000. Mekong River Pangasiidae catfish migration and the Khone falls wings trap fishery in Southern Lao. Environmental Protection and Community Development in the Siphandone Wetland Project Champasak Province, LaosP.D.R.

កំណត់ចំណាំ:

ត្រីប្រាធំទំហំធំចាប់ពី៣/៤គក្រឡើងទៅ(ក្នុងប្រអប់ពណ៌លឿង)ធ្វើបន្លាស់ទីចេញពីព្រៃលិចទឹកមកលំហកណ្តាលបឹងទន្លេសាបនៅអំឡុងខែសីហា-កញ្ញា ហើយចាកចេញពីបឹងធ្វើដំណើរតាមដងទន្លេសាបចុះទៅរកទន្លេសមេគង្គជាទីដែលត្រីមួយចំនួនធំបន្តដំណើរ ទៅតំបន់ខាងលើទន្លេសមេគង្គ និងមួយចំនួនតូចបន្តចុះតាមទន្លេសមេគង្គទៅផ្នែកខាងក្រោមដែលអ្នកនេសាទតែងបានក្បែរខាងអន្លង់ធំកន្ទុយ កោះកន្ទាយ (ប្រអប់ពណ៌បៃតង)។ ចាប់ពីខែមករាដល់មិថុនា ត្រីធំៗដែលឡើងទៅផ្នែកខាងលើទន្លេមេគង្គមួយចំនួនធំឡើងហួសទៅដល់តំបន់អន្លង់ទឹកជួរព្រែអញ្ចែងខេត្តក្រចេះនិងមួយចំនួនតូចនៅសំងំតាមអន្លង់ជ្រៅៗក្នុងខេត្តកំពង់ចាម (ប្រអប់ពណ៌បៃតង)។ ជាសំខាន់ត្រី ធំៗដែលចាប់បានដោយ ការរាយសន្ទូចរនង នៅពេលជំនន់ធំទន្លេមេគង្គ ជាលើកតំបូងនៅរដូវវស្សា (ជន់ឡើង២-៣ម៉ែត្រក្នុងរយៈ៥-៦ម៉ោង ហើយនៅទ្រឹងមួយថ្ងៃ ឬពីរថ្ងៃ រួចស្រកទៅវិញប្រហែល១-១,៥ម៉ែត្រ) សុទ្ធតែជាត្រីឈ្មោលដែលមានស្តាំមនៅហូរចេញពីប្រដាប់បន្តពូជនៅឡើយដែលបញ្ជាក់ថាពួកវាទើបតែបញ្ចេញស្តាំមផ្តលមេជីវិតឲ្យពងដែលត្រីមេទម្លាក់ជាលើកទីមួយរួច។ ត្រីដែលនៅតូចមិនទាន់ពេញវ័យ បន្តពូជ (ប្រអប់ពណ៌ខៀវ) ចេញពីតំបន់ព្រៃលិចទឹកពេលធ្លាក់ខ្យល់កត្តិកចុងខែវិច្ឆិកាឬខែធ្នូ ត្រូវជាប់នៅក្នុងបឹងទន្លេសាបចំពោះត្រីនៅតំបន់ នោះ ឯត្រីនៅតំបន់ទំនាបផ្សេងទៀតចាកចេញតាមផ្លូវទឹកនានាទៅរកតំបន់ទឹកជ្រៅ ឬទន្លេធំដែលមានទឹកជ្រៅ។ កូនត្រីប្រាម្សៅ (ប្រអប់ពណ៌ ត្នោត) ដែលនេសាទបាននៅតាមដងទន្លេមេគង្គ និងដងទន្លេតូចចាប់ពីចុងខែមិថុនាដល់ចុងខែសីហាដូចក្នុងតារាង៥ខាងក្រោម។

### ២.២.៤. លទ្ធផលយកសំណាកគំរូក្រពេញបន្តពូជ សារធាតុខ្លាញ់ និងចំណីក្នុងក្រពះ/ពោះវៀនត្រី

ការចុះយកសំណាកគំរូត្រីប្រាធដើម្បីវះកាត់ពិនិត្យកំរិតក្រពេញបន្តពូជសារធាតុខ្លាញ់ក្នុងពោះសារធាតុចំណីក្នុងក្រពះនិងពោះវៀន (រូបភាព៦និង៧) និងកំណត់អត្រាភេទ ត្រូវធ្វើនៅតាមកន្លែង នេសាទតំណាងឲ្យតំបន់បឹងទន្លេសាប ដងទន្លេសាប ដងទន្លេមេគង្គលើ តំបន់ទឹកជួរទន្លេមេគង្គលើ ដងទន្លេមេគង្គក្រោមនិងតំបន់ទំនាបជុំវិញ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត វិលជុំពេញ មួយឆ្នាំ ប៉ុន្តែត្រីដែលរើសយកវះកាត់វិភាគតាមទំហំខ្នាតនិមួយៗមានចំនួនមិនទៀងទាត់ដូចជាមានចំនួនច្រើននៅទសវត្សឆ្នាំ៨០ដោយសារអ្នកនេសាទធ្វើអំណោយនិងមានចំនួនតិចតួចនៅទសវត្សឆ្នាំ៩០ដោយសារផលត្រីបានថយចុះធ្វើឲ្យតម្លៃឡើងខ្ពស់ ដែលតម្រូវឲ្យត្រូវចំណាយប្រាក់ទិញយកមកវះកាត់៖

- ការវះកាត់ត្រីប្រាធំទាំងតូចទាំងធំនៅក្នុងបឹងទន្លេសាបក្នុងអំឡុងខែសីហា-កញ្ញា បានរកឃើញថា ត្រីនិមួយៗមានចំណីពេញក្រពះនិងពោះវៀន និងមានខ្លាញ់ពេញពោះ ឯក្រពេញបន្តពូជនៅពុំ ទាន់រីកលូតលាស់នៅឡើយ។ ការវះកាត់នៅរដូវប្រាំងចាប់ពីខែវិច្ឆិកាដល់ឧសភា ក៏បានឲ្យដឹងថា ចំណីក្នុងក្រពះ និងពោះវៀននៃត្រីទាំងអស់បានថយចុះជាបន្តបន្ទាប់រហូតនៅសល់តែ២០-១០% ប៉ុណ្ណោះ ឯខ្លាញ់ពោះ ស្ទើរតែគ្មាន ហើយក្រពេញបន្តពូជក៏គ្មានការរីកចំរើនដែរ។

- ការវះកាត់ត្រីប្រាធំទាំងតូចទាំងធំនៅតាមដងទន្លេសាប ចាប់ពីមាត់ពាមបឹងទន្លេសាបទៅដល់ទន្លេចតុមុខក្នុងអំឡុងខែតុលា-កុម្ភៈ បានរកឃើញថាត្រីនិមួយៗមានចំណីក្នុងក្រពះនិងពោះវៀនកំរិត III មានខ្លាញ់ពោះកំរិត II-III ឯក្រពេញបន្តពូជនៅពុំទាន់រីកលូតលាស់នៅឡើយ។ ឯការវះ កាត់ត្រីប្រាធំនៅរដូវប្រាំងចាប់ពីខែមិនាដល់ឧសភា បានឲ្យដឹងដែរថាចំណីក្នុងក្រពះនិងពោះវៀន មាន កំរិត I-II ហើយខ្លាញ់ពោះមានកំរិត I ឯក្រពេញបន្តពូជក៏មិនមានការរីកលូតលាស់ដែរ។

- ការវះកាត់ត្រីប្រាធំទាំងតូចទាំងធំ ដែលនេសាទបានតាមដងទន្លេមេគង្គក្រោមចាប់ពីទន្លេចតុមុខទៅដល់ព្រំប្រទល់កម្ពុជា-វៀតណាមក្នុងអំឡុងខែតុលា-កុម្ភៈ បានរកឃើញថាត្រីនិមួយៗមាន ចំណីក្នុងក្រពះនិងពោះវៀនកំរិត III ហើយមានខ្លាញ់ពោះកំរិត II ឯក្រពេញបន្តពូជនៅពុំទាន់រីក លូតលាស់នៅឡើយ។ ឯការវះកាត់ត្រីប្រាធំនៅអំឡុងខែមិនា-ឧសភា បានឲ្យដឹងដែរថាចំណីក្នុង ក្រពះនិងពោះវៀនមានកំរិត I-II ហើយខ្លាញ់ពោះមានកំរិត I ឯក្រពេញបន្តពូជរបស់ត្រីទំហំតូច ជាង៣គក្រមិនមានការរីកចំរើនទេ តែត្រីធំជាង៣គក្រមានក្រពេញបន្តពូជរីកចំរើនកំរិត III - IV។

- ការវះកាត់ត្រីប្រាធំទាំងតូចទាំងធំដែលនេសាទបានតាមដងទន្លេមេគង្គលើចាប់ពីទន្លេចតុមុខ ទៅដល់តំបន់ទឹកជួរព្រៃអញ្ចែងខេត្តក្រចេះជាប់ព្រំប្រទល់ខេត្តស្ទឹងត្រែងក្នុងអំឡុងខែតុលា-កុម្ភៈបានបង្ហាញថាត្រីនិមួយៗមានចំណីក្នុងក្រពះនិងពោះវៀនកំរិត II-III ហើយមានខ្លាញ់ពោះកំរិត I-II ឯក្រពេញបន្តពូជនៅពុំទាន់រីកចំរើននៅឡើយ។ឯការវះកាត់ត្រីប្រាធំនៅអំឡុងខែមិនា-ឧសភាបានឲ្យដឹងដែរថាចំណីក្នុងក្រពះនិងពោះវៀនមានកំរិត 0-I ហើយខ្លាញ់ពោះមានកំរិត 0 ឯក្រពេញបន្តពូជ(ត្រីធំជាង៥គក្រ) រីកចំរើនកំរិត IV - V។

លទ្ធផលនៃការយកសំណាកគំរូត្រីប្រាធំនៅតាមតំបន់ស្រាវជ្រាវទាំងអស់ទូទាំងប្រទេស មានរាយនៅក្នុងតារាង៤ខាងក្រោម៖

## តារាង៤. អត្រាភេទ(ញីឈ្មោល) កំរិតក្រពេញបន្តពូជ សារធាតុខ្លាញ់ ចំណីក្នុងក្រពះ/ពោះវៀននៃត្រីប្រាធំ

| តំបន់ នេសាទ / ពេលវេលា | តំបន់បឹងទន្លេសាប | ដងទន្លេសាប | ដងទន្លេមេគង្គលើ | ដងទន្លេមេគង្គក្រោម |
|---|---|---|---|---|
| កក្កដា - កញ្ញា | ចំនួនត្រីសំណាកគំរូ: ១០០<br>ទំហំ ៤ - ១០គក្រ<br>អត្រាភេទ: ១/៣<br>ក្រពេញបន្តពូជ: I<br>កំរិតខ្លាញ់: IV<br>ចំណុះចំណីក្នុងក្រពះ: III<br>ចំណុះចំណីក្នុងពោះវៀន: IV | | ចំនួនត្រីសំណាកគំរូ: ២០០<br>ទំហំ ៤ - ៨គក្រ<br>អត្រាភេទ: ឈ្មោលទាំងអស់<br>ក្រពេញបន្តពូជ: VII<br>កំរិតខ្លាញ់: 0 - ១<br>ចំណុះចំណីក្នុងក្រពះ: I<br>ចំណុះចំណីក្នុងពោះវៀន: 0<br>(វាយសន្ទូចនេងនៅចុងខែមិថុនា) | |
| តុលា - ធ្នូ | ចំនួនត្រីសំណាកគំរូ: ២០០<br>ទំហំ ០,២ - ៣គក្រ<br>អត្រាភេទ: ១/២<br>ក្រពេញបន្តពូជ: I<br>កំរិតខ្លាញ់: III - IV<br>ចំណុះចំណីក្នុងក្រពះ: III<br>ចំណុះចំណីក្នុងពោះវៀន: IV | ចំនួនត្រីសំណាកគំរូ: ១០០<br>ទំហំ ៤ - ៨គក្រ<br>អត្រាភេទ: ១/៣<br>ក្រពេញបន្តពូជ: I<br>កំរិតខ្លាញ់: IV<br>ចំណុះចំណីក្នុងក្រពះ: III<br>ចំណុះចំណីក្នុងពោះវៀន: IV | | |
| មករា - មិនា | ចំនួនត្រីសំណាកគំរូ: ១០០<br>ទំហំពី ០,៣ - ២គក្រ<br>អត្រាភេទ: ១/២<br>ក្រពេញបន្តពូជ: I<br>កំរិតខ្លាញ់: II<br>ចំណុះចំណីក្នុងក្រពះ: II - III<br>ចំណុះចំណីក្នុងពោះវៀន: II | ចំនួនត្រីសំណាកគំរូ: ១០០ ទំហំពី ២ - ៤គក្រ<br>អត្រាភេទ: ១/៣<br>ក្រពេញបន្តពូជ: I<br>កំរិតខ្លាញ់: II<br>ចំណុះចំណីក្នុងក្រពះ: II<br>ចំណុះចំណីក្នុងពោះវៀន: III | ចំនួនត្រីសំណាកគំរូ: ៣០<br>ទំហំពី ០,៤ - ៦គក្រ<br>អត្រាភេទ: ១/២<br>ក្រពេញបន្តពូជ: I - II<br>កំរិតខ្លាញ់: III - IV<br>ចំណុះចំណីក្នុងក្រពះ: III<br>ចំណុះចំណីក្នុងពោះវៀន: IV | ចំនួនត្រីសំណាកគំរូ: ២០<br>ទំហំពី ០,៥ - ៤គក្រ<br>អត្រាភេទ: ១/២<br>ក្រពេញបន្តពូជ: I - II<br>កំរិតខ្លាញ់: II<br>ចំណុះចំណីក្នុងក្រពះ: II<br>ចំណុះចំណីក្នុងពោះវៀន: III - IV |
| មេសា - មិថុនា | ចំនួនត្រីសំណាកគំរូ: ២០០<br>ទំហំពី ០,៥ - ៤គក្រ<br>អត្រាភេទ: ១/២<br>ក្រពេញបន្តពូជ: I<br>កំរិតខ្លាញ់: II<br>ចំណុះចំណីក្នុងក្រពះ: II<br>ចំណុះចំណីក្នុងពោះវៀន: I - II | ចំនួនត្រីសំណាកគំរូ: ២០<br>ទំហំពី ១ - ៥គក្រ<br>អត្រាភេទ: ១/២<br>ក្រពេញបន្តពូជ: I<br>កំរិតខ្លាញ់: I<br>ចំណុះចំណីក្នុងក្រពះ: II<br>ចំណុះចំណីក្នុងពោះវៀន: III | ចំនួនត្រីសំណាកគំរូ: ៣០<br>ទំហំពី ៤ - ១០គក្រ<br>អត្រាភេទ: ១/៣<br>ក្រពេញបន្តពូជ: IV - V<br>កំរិតខ្លាញ់: 0<br>ចំណុះចំណីក្នុងក្រពះ: 0 - I<br>ចំណុះចំណីក្នុងពោះវៀន: 0 - I | ចំនួនត្រីសំណាកគំរូ: ២០<br>ទំហំពី ១ - ៣គក្រ<br>អត្រាភេទ: ១/២<br>ក្រពេញបន្តពូជ: I<br>កំរិតខ្លាញ់: I<br>ចំណុះចំណីក្នុងក្រពះ: I - II<br>ចំណុះចំណីក្នុងពោះវៀន: II |

កំណត់សំគាល់:

**កំរិតក្រពេញបន្តពូជ:** I = នៅព្រហ្មចារី,ក្រពេញអូរូលថ្លាពីគ្មានព៌ណទៅប្រផេះ; II = ព្រហ្មចារីចំណាស់; III = ចាប់កពងឬស្តើម,ក្រពេញអូរូលរីក; IV = បន្តកពង ឬស្តើម , ក្រពេញអូរូលឡើងគ្រាប់ៗ; V = គ្រាប់ពងករកូនដោយមានចំណុច ខ្មៅលេចឡើង; VI = ដំណាក់កាលទម្លាក់ពងឬបញ្ចេញស្តើម; VII =ទម្លាក់ពងលើក ទី១រួច ឯត្រីឈ្មោលវិញបញ្ចេញស្តាំមរួចនៅមានស្តាំមហូរចេញពីប្រដាប់បន្តពូជ; VIII = ទម្លាក់ពងលើកទី២រួចនៅសល់ពងប្រហែល៣០% ត្រូវរាគចោល

**កំរិតសារធាតុខ្លាញ់ក្នុងពោះ:** 0 = មិនទាន់ករកើតដុំខ្លាញ់; I = ដុំខ្លាញ់ករកើតតិចតួច; II = ដុំខ្លាញ់ករកើតប្រហែលពាក់ កណ្តាលផ្ទៃពោះ; III = ដុំខ្លាញ់ករកើត ពេញផ្ទៃពោះ; IV = ដុំខ្លាញ់ករកើតណែនផ្ទៃពោះ

**កំរិតចំណុះក្រពះ:** 0 = ក្រពះទទេ; I = មានចំណីតិចតួច; II = មានចំណីពាក់កណ្តាលពោះ; III = មានចំណីពេញពោះ; IV = មានចំណីណែនពោះអាចមើលឃើញចំណីក្នុងពោះ

**កំរិតចំណុះពោះវៀន**: 0 = គ្មានចំណីសោះពោះវៀនតូចហើយខ្ចី; I = ចំណីមានតិចតួច; II = មានចំណីពាក់កណ្តាលពោះវៀន; III= មានចំណីពេញពោះវៀន ជាធម្មតាតែងទាក់ទងទៅនឹងចំណុះចំណីក្នុងក្រពះកំរិត I ឬ II; IV = មានចំណីណែនពោះវៀនមើលឃើញដល់ក្នុងពោះវៀនប៉ោងធំហើយលូតវែងដែលជា ធម្មតាតែងទាក់ទងទៅនឹងចំណុះក្រពះកំរិត III ឬ IV ។




រូបភាព៦. ត្រីប្រាធំឈ្មោល ប្រវែង០,៨៦ម ទម្ងន់៦,៥ នេសាទបាននាដើមខែឧសភា នៅកោះ រងាវ ស្រុកសំបូរ ខេត្តក្រចេះ (ក្រពេញបន្តពូជកំរិត III; ចំណុះចំណីក្នុងក្រពះកំរិត I; ចំណុះចំណីក្នុងពោះវៀនកំរិត I)




រូបភាព៧. ត្រីប្រាធំឈ្មោល ប្រវែង០,៧៩ម ទម្ងន់៤,៧គក្រ នេសាទបាននាដើមខែឧសភានៅអន្លង់ព្រះប្រលិច ស្រុកសំបូរ ខេត្តក្រចេះ (ក្រពេញបន្តពូជកំរិត II; ចំណុះចំណីក្នុងក្រពះកំរិត II; ចំណុះចំណីក្នុងពោះវៀនកៅរិត II)

## ២.២.៥. លទ្ធផលនៃការចុះអង្កេតការនេសាទកូនត្រីប្រាម្សៅទាក់ទងនឹងរបបទឹកជំនន់ទន្លេមេគង្គ

ការនេសាទកូនត្រីប្រាម្សៅដោយប្រើឧបករណ៍ដាយស្បៃមុងមានរាងជាចង់ទ្រវែងវៀវខាងចុងជាកន្លែងត្រងចាប់កូនត្រី មាត់បើកទទឹង៥ម៉ែត្រនិងជម្រៅតាមជម្រៅទឹកបញ្ច្រាស់ខ្សែទឹក។ ដាយត្រូវតម្លើង បន្តជាប់គ្នាជាជួរ ដែលក្នុងមួយជួរៗ មាន៣ទៅ៧មាត់ដាយ អាស្រ័យតាមកន្លែងដែលដែលទឹកហូរខ្លាំង។
ការនេសាទកូនត្រីប្រាម្សៅចាប់ផ្តើមនៅពេលជំនន់ទន្លេមេគង្គហក់ឡើងជាតំបូងក្នុងអំឡុងខែមិថុនាដោយប្រើរយៈពេលពី៤-៥ថ្ងៃ អាស្រ័យទៅតាមវត្តមានកូនត្រីម្សៅ។ សកម្មភាពនេះត្រូវអនុវត្តចំនួន២លើកទៀត ពេលជំនន់ទន្លេមេគង្គទី២និងទី៣ ដែលនឹងត្រូវកើតឡើងក្នុងចន្លោះពី១០ទៅ២០ថ្ងៃជាបន្តបន្ទាប់គ្នា ក្រោយមក។
ការអង្កេតលើកទី១នាអំឡុងឆ្នាំ១៩៨១និង១៩៨២:កូនត្រីប្រាម្សៅដែលនេសាទបានក្នុងមួយរដូវមានបរិមាណប្រហាក់ប្រហែលគ្នា ដោយដាយនិមួយៗ អាចនេសាទបាន ពី២០ទៅ៣០លានកូនត្រី ម្សៅក្នុងមួយរដូវ។
ការអង្កេតលើកទី២ នាឆ្នាំ១៩៩០ និង១៩៩១: ទីតាំងនេសាទដាយកូនត្រីប្រាម្សៅបានរីក សាយរហូតទៅដល់ខេត្តកំពង់ចាមនិងក្រចេះតំបន់ទន្លេមេគង្គលើហើយចំនួនឧបករណ៍ដាយក៏កើនឡើងជិត២ដងតែកូនត្រីដែលនេសាទបានជាសរុបមានការថយចុះជិតពាក់កណ្តាល(តារាងលេខ៥)បើប្រៀបធៀបទៅនឹងទសវត្សឆ្នាំ៨០។
ជាអំណោយដល់ការស្រាវជ្រាវនេះ នៅឆ្នាំ១៩៩១ ទិន្នន័យជលសាស្រ្ត ទន្លេមេគង្គត្រូវបានកត់ត្រាដោយនាយកដ្ឋានជលសាស្រ្ត និងធារាសាស្រ្តនៃក្រសួងកសិកម្ម ជាពិសេស ទិន្នន័យនៅស្ថានីយ៍ខេត្តស្ទឹងត្រែង ចតុមុខ និងអ្នកលឿងដែលចាំបាច់សម្រាប់វិភាគពេលវេលាទម្លាក់ ពងកូនរបស់ត្រីប្រានិងទំនាក់ទំនងជាមួយពេលវេលានេសាទកូនត្រីប្រាម្សៅនៅខ្សែទឹកខាងក្រោម (សូមមើលរូបភាព៨ខាងក្រោម)។




រូបភាព៨បានបង្ហាញឲ្យឃើញថាទឹកជំនន់ធំរបស់ទន្លេមេគង្គតំបូងនៅស្ទឹងត្រែងនៅថ្ងៃ២១មិថុនា ហើយ កូនត្រីប្រាម្សៅទំហំ១ - ២សម (អាយុប្រហែលជាង១០ថ្ងៃ) ត្រូវគេនេសាទបានជាតំបូងនៅខាងក្រោមអ្នកលឿងនៅថ្ងៃ២៧-៣០ខែមិថុនាឆ្នាំ១៩៩១នៅពេលជំនន់ទី២ចាប់ផ្តើមហក់ឡើង។ ជំនន់ទី២ហក់ឡើងដល់កំរិតកំពូលនៅស្ទឹងត្រែងនៅថ្ងៃទី៥ ខែកក្កដា ហើយកូនត្រីប្រាម្សៅទំហំ២-៣សម (អាយុប្រហែលជាង១០ថ្ងៃ) ត្រូវគេនេសាទបាននៅខាងក្រោមអ្នកលឿងនៅថ្ងៃទី២០-២៤ខែកក្កដាឆ្នាំ១៩៩១នៅពេលជំនន់ទី៣ ចាប់ផ្តើមហក់ឡើង។ជំនន់ទី៣ហក់ឡើង ដល់កំរិតកំពូលនៅស្ទឹងត្រែងនៅថ្ងៃទី២២ ខែកក្កដា ឯកូនត្រីប្រាម្សៅទំហំ២-៣សម (អាយុប្រហែលជាង១០ថ្ងៃ) ត្រូវគេនេសាទបាននៅខាងក្រោមអ្នកលឿង នៅថ្ងៃទី៥-១០ ខែសីហាឆ្នាំ១៩៩១នៅពេលជំនន់ទី៤ចាប់ផ្តើមហក់ឡើង។

ទំនាក់ទំនងនៃព័ត៌មានខាងលើនេះ អាចបញ្ជាក់ថាត្រីប្រាធំទម្លាក់ពងនៅពេលជំនន់ទន្លេមេគង្គ ហក់ឡើងដល់កំរិតកំពូលម្តងៗ។ កូនត្រីដែលទើបនឹងញាស់រស់នៅក្នុងសំបុកមួយរយៈរហូតដល់ជំនន់ថ្មី មកដល់រុញពួកវាចុះតាមចរន្តទឹកមកក្រោម។

**ការអង្កេតលើកទី៣ នាឆ្នាំ១៩៩៧ និង១៩៩៨:** ទីតាំងនេសាទនិងចំនួនដាយមានដូចគ្នានឹងការអង្កេតលើកទី២ តែផលកូនត្រីប្រាម្សៅបានធ្លាក់ចុះក្រោម២០%បើប្រៀបធៀបទៅនឹងឆ្នាំ១៩៨១-៨២ (តារាង លេខ ៥)។

រូបភាព៩ ទិន្នន័យជលសាស្ត្រពីថ្ងៃ១មករាដល់៣១ធ្នូ ដែលកត់ត្រានៅស្ថានីយ៍ខេត្តស្ទឹងត្រែង អ្នកលឿង និងចតុមុខ ឆ្នាំ១




រូបភាព៩បានបង្ហាញឲ្យឃើញថា ទឹកជំនន់ធំរបស់ទន្លេមេគង្គតំបូងនៅស្ទឹងត្រែងនៅថ្ងៃ១៥មិថុនា ហើយកូនត្រីប្រាម្បៀទំហំ២-៣សម (អាយុប្រហែលជាង២០ថ្ងៃ) ត្រូវគេនេសាទបានជាតំបូង នៅខាងក្រោម អ្នកលឿង នៅថ្ងៃ៩-១៣ខែមិថុនាឆ្នាំ១៩៩៨នៅពេលជំនន់ទី២ចាប់ផ្ដើមហក់ឡើង។ ជំនន់ទី២ហក់ឡើងដល់កំរិតកំពូលនៅស្ទឹងត្រែង នៅថ្ងៃទី១៥កក្កដា ហើយកូនត្រីប្រាម្បៀទំហំ៤ - ៥សម (អាយុប្រហែលជាង៣០ថ្ងៃ) ត្រូវគេនេសាទបាននៅខាងក្រោមអ្នកលឿងនៅថ្ងៃទី២៤ខែសីហាឆ្នាំ១៩៩៨នៅពេលជំនន់ទី៣ហក់ឡើងចុះជាច្រើនដងយឺតយ៉ាវជាងធម្មតានៅក្នុងខែសីហាដែលធ្វើឲ្យការនេសាទកូនត្រីប្រាម្បៀជួបការរអាក់រអួលយ៉ាងខ្លាំងនិងទទួលបានផលតិចតួចបំផុត។

ទំនាក់ទំនងនៃព័ត៌មានខាងលើនេះ អាចបញ្ជាក់ពីការប្រែប្រួលនៃរបបទឹកជំនន់ទន្លេមេគង្គយ៉ាងខ្លាំងដោយសារទំនប់វារីអគ្គិសនីដែលសាងសង់នៅផ្នែកខាងលើទន្លេ ដែលអាចប៉ះពាល់ដល់ទម្លាប់ពង កូនរបស់ត្រីប្រាធំ គួបផ្សំនឹងការថយចុះជាបនតបន្ទាប់នៃចំនួនមេពូជត្រីប្រាធំចាប់តាំងពីមានការនេសាទ ដាយត្រីតាមដងទន្លេសាប និងការនេសាទកូនត្រីប្រាម្បៀតាមដងទន្លេមេគង្គ។

តារាង.៥. បរិមាណកូនត្រីប្រាម្បៀដែលនេសាទបានតាមឆ្នាំដែលបានកត់ត្រា

| ឆ្នាំ | តំបន់ | ចំនួនដាយកូនត្រី | ដំណាក់កាលនេសាទកូនត្រីប្រាម្បៀ | | | | | | | | | | | | សរុប (ពាន់លានក្បាល) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនកូនត្រីចាប់នៅខែមិថុនា (ពាន់លានក្បាល) | | | | ចំនួនកូនត្រីចាប់នៅខែកក្កដា (ពាន់លានក្បាល) | | | | ចំនួនកូនត្រីចាប់នៅខែសីហា (ពាន់លានក្បាល) | | | | |
| | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | |
| ១៩៨១ | មេគង្គ | ៥០០ | | | | ៤ | | ៦ | | ៥ | | | | | ១៥ |
| | ទន្លេតូច | ១៥០ | | | | ០,៦ | | ០,៨ | | ០,៦ | | | | | ២ |
| ១៩៨២ | មេគង្គ | ៥០០ | | | | | ៤,៥ | | ៧ | | ៦,៥ | | | | ១៨ |
| | ទន្លេតូច | ១៥០ | | | | | ០៥ | | ១ | | ០,៩ | | | | ២,៤ |
| ១៩៩០ | មេគង្គ | ៦៥០ | | | | ៣ | | ៣,៥ | | ៤,៥ | | | | | ១១ |
| | ទន្លេតូច | ១៥០ | | | | ០,២ | | ០,៣ | | ០,៣ | | | | | ០,៨ |
| ១៩៩១ | មេគង្គ | ៦៥០ | | | | ៤ | | | | ៤,៥ | | | ៣,៥ | | ១២ |
| | ទន្លេតូច | ១៥០ | | | | ០,៣ | | | | ០,៣៥ | | | ០,២៥ | | ០,៩ |
| ១៩៩៧ | មេគង្គ | ៨០០ | | | | | | ៣ | | ២ | | | | | ៥ |
| | ទន្លេតូច | ១៥០ | | | | | | ០,៣ | | ០,២ | | | | | ០,៥ |
| ១៩៩៨ | មេគង្គ | ៨០០ | | | | | | ២ | | | | | | ០,៥ | ២,៥ |
| | ទន្លេតូច | ១៥០ | | | | | | ០,២ | | | | | | ០០៤ | ០,២៤ |

កំណត់ចំណាំ:

ការនេសាទកូនត្រីប្រាមៀនាវដូវឆ្នាំ១៩៩៧ធ្វើបានតែ២លើកប៉ុណ្ណោះ ហើយកូនត្រីដែលនេសាទបានក៏ថយចុះយ៉ាងខ្លាំង ជាពិសេសនៅឆ្នាំ១៩៩៨ដែលការនេសាទនៅជំនន់ទី១មានការរអាក់រអួលខ្លាំងដោយបរិមាណកូនត្រីដែលចាប់បានតិចតួចហើយ អ្នកនេសាទត្រូវរង់ចាំរហូតដល់ជាងមួយខែទើបនេសាទកូនត្រីបានក្នុងចំនួនតិចតួចបំផុតដែលធ្វើឲ្យបរនេះទទួលការខាតបង់យ៉ាងច្រើន។

## ២.២.៦. វិយបន្តពូជ ការរីកលូតលាស់នៃក្រពេញបន្តពូជ និងកន្លែងពងកូនរបស់ត្រីប្រាធំ

ការអង្កេតពីវត្តមានរបស់ត្រីប្រាធំ នៅតាមទីកន្លែងទាំងឡាយក្នុងប្រព័ន្ធទឹកសាប និងតាមពេល វេលាខុសៗគ្នាក្នុងឆ្នាំ បានបង្ហាញឲ្យឃើញថាត្រីប្រាធំទំហំចាប់ពី៤គក្រ (ត្រីឈ្មោល) ឬជាង៤គក្រ (ត្រីញី) ឡើងទៅ ដែលសំងំលាក់ខ្លួននៅអន្លង់ជ្រៅៗនៅតាមដងទន្លេមេគង្គ ជាពិសេសក្នុងតំបន់ទឹកជួរ ក្នុងខេត្តក្រចេះនៅរដូវប្រាំងដែលមានទឹកថ្លានិងមិនសូវមានការរំខានដោយការនេសាទ  បានអភិវឌ្ឍក្រពេញបន្តពូជនៅអំឡុងខែមេសា-មិថុនានៃឆ្នាំ។ឯក្រពេញបន្តពូជនៃត្រីទំហំដូចគ្នានេះនៅតំបន់ផ្សេងទៀតមិនបានអភិវឌ្ឍក្រពេញបន្តពូជឡើយដោយសារស្ថានភាពទឹកកករល្អក់នៃជំរកនៅរដូវប្រាំង និងរង ការរំខានពីការនេសាទដ៏ច្រើនផង។

ចំណុចសំខាន់មួយទៀតគឺការរាយសន្ទូចរនងចាប់បានត្រីប្រាធំឈ្មោលដែលមានទឹកកាមនៅហូរចេញតាមប្រដាប់បន្តពូជនៅថ្ងៃដែលទឹកជំនន់ទន្លេកេគង្គហក់ឡើងតំបូងនៅដើមរដូវវស្សានៅតំបន់ទឹកជួរព្រៃអញ្ចែងដ៏ធំក្នុងខេត្តក្រចេះជាប់ព្រំប្រទល់ខេត្តស្ទឹងត្រែង  ដែលអាចសន្និដ្ឋានបានថាតំបន់នេះជាកន្លែង  ពងកូនរបស់ត្រីប្រាធំ ព្រោះថាឫសអញ្ចែងដែលនៅខាងលើដីនៅពេលទឹកតម្លើងអាចក្លាយជាសំបុក សុវត្ថិភាពរបស់ត្រីប្រានៅពេលទម្លាក់ពងនិងទទួលមេជីវិត(ពងត្រីប្រាធំស្អិតភ្ជាប់ទៅនឹងឫសអញ្ចែងរយៈពេលពី១៨-២២ម៉ោងទើបញាស់ អាស្រ័យទៅតាមសីតុណ្ហភាពទឹកពី២៧-២៣អង្សាសេ)។ កូនត្រីដែល ទើបនឹងញាស់ត្រូវរស់នៅក្នុងសំបុកឫសអញ្ចែងមួយរយៈ  រហូតដល់ជំនន់បន្ទាប់ហក់ឡើងម្តងទៀតទើប  រុញច្រានកូនត្រីទាំងនោះចេញពីសំបុកចុះតាមចរន្តទឹកទៅខាងក្រោម ដោយទុកសំបុកឲ្យមេពូជផ្សេង ទៀតចូលមកទម្លាក់ពង (រូបភាព១០, ១១, ១២ និង១៣)។



រូបភាព១០. ដើមអញ្ចែង (Gimenila asiatica)



រូបភាព១១. ព្រៃអញ្ចែងនៅតំបន់ទឹកជួរ



រូបភាព១២. ឫសអញ្ចែងនៅខាងលើដីជាសំបុកពងកូនសុវត្ថិភាពរបស់ត្រីប្រាធំ




រូបភាព១៣. ផែនទីបង្ហាញពីតំបន់ទឹកជួរព្រៃអញ្ចេងដែលជាកន្លែងពងកូនរបស់ត្រីប្រាធំតែមួយគត់

## ៣. ការវិភាគព័ត៌មាននិងទិន្នន័យជីវសាស្ត្ររបស់ត្រីប្រាធំទាក់ទងនឹងបន្លាស់ទីទៅស៊ីចំណី និងបន្តពូជ

ព័ត៌មាននិងទិន្នន័យដែលស្រង់ចេញពីការស្រាវជ្រាវអង្កេតស៊ីជំរៅក្នុងរយៈពេល២០ឆ្នាំនេះ បានបង្ហាញពីភាពច្រំដែលនៃលក្ខខណ្ឌរស់នៅរបស់ត្រីប្រាធំនៅតាមកន្លែងនិងដំណាក់កាលនិមួយៗ ដែលពួកវាមានវត្តមានដែលអាចឲ្យកំណត់បានពីការធ្វើបន្លាស់ទីទៅរកកន្លែងស៊ីចំណីនិងទៅរកកន្លែងពងកូនបន្តពូជរបស់ពួកវា។

ព័ត៌មាននិងទិន្នន័យទាំងអស់នោះបានឲ្យដឹងថាត្រីធំៗដែលក្នុងនោះមានត្រីប្រាធំទំហំចាប់ពី៤-៥គក្រឡើងទៅបានចាកចេញពីព្រៃលិចទឹកជុំវិញបឹងទន្លេសាបមកលំហរកណ្តាលបឹងនៅអំឡុងខែសីហាក្រោយពីបានស៊ីចំណីពេញពោះនៅដើមរដូវវស្សា។ ត្រីទាំងនោះបានបន្តដំណើរចេញពីបឹងទន្លេ សាបតាមគន្លងផ្លូវទឹកជ្រៅនៅតំបន់មាត់ពាម រួចបន្តតាមដងទន្លេសាបរហូតដល់ទន្លេចតុមុខ ដែលជាកន្លែងជួបប្រសព្វគ្នាជាមួយទន្លេមេគង្គ។ ត្រីធំៗរួមទាំងត្រីប្រាធំមួយចំនួនធំផងនោះ បានឡើងបញ្ច្រាស់ ខ្សែទឹកឆ្ពោះទៅតំបន់ទន្លេមេគង្គលើជាទីដែលមានទឹកថ្លាចរន្តទឹកខ្លាំងនិងមានអន្លង់ជ្រៅៗនៅក្នុងតំបន់ព្រៃអញ្ចេងក្នុងខេត្តក្រចេះជិតព្រំប្រទល់ខេត្តស្ទឹងត្រែងដែលជាជំរកដ៏សុខដុមសម្រាប់ការរីកលូតលាស់នៃក្រពេញបន្តពូជរបស់ពួកវាតែក៏មានមួយចំនួនបានឈប់សំចតនៅតាមអន្លង់ជ្រៅនៅតាមផ្លូវក្នុងខេត្តកំពង់ចាមដែរ។ យ៉ាងណាក៏ដោយក៏មានត្រីធំៗរួមទាំងត្រីប្រាធំមួយចំនួនផង បានបន្តចុះតាមបណ្តោយខ្សែទឹកទៅតំបន់ទន្លេមេគង្គក្រោមដែរ។

ចំណែកឯត្រីប្រាធំទំហំ៤គក្រចុះ បានចេញពីព្រៃលិចទឹកជុំវិញបឹងទន្លេសាប នៅរដូវរំហើយធ្លាក់ខ្យល់ពីជើង(ខែវិច្ឆិកា-ធ្នូ)ហើយត្រូវរស់នៅពេញមួយរដូវប្រាំងក្នុងលំហរកណ្តាលបឹងទន្លេសាបមិនអាចបន្តដំណើរទៅរកកន្លែងមានទឹកជ្រៅបានដោយសារទឹករាក់នៅតំបន់មាត់ពាមបឹងទន្លេសាប។ ពពួកត្រីប្រាធំទំហំដូចគ្នាដែលរស់នៅក្នុងអន្លង់តាមដងទន្លេសាប ទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេតូច នៅរដូវ ប្រាំងត្រូវហែលចូលទៅបឹងទន្លេសាបវិញដើម្បីស៊ីចំណីនៅរដូវវស្សា (សូមមើលរូបភាពផែនទីលេខ១៤)។




**រូបភាព១៤**ផែនទីបង្ហាញអំពីផ្លូវធ្វើបន្លាស់ទីទៅស៊ីចំណីនិងកន្លែងស៊ីចំណីទៅពងកូននិងកន្លែងពងកូនរបស់ត្រីប្រាធំ

## ២.២.៦. បរិមាណត្រីប្រាធំដែលបានស្រាវជ្រាវអង្កេតនៅអំឡុងទសវត្សឆ្នាំ៨០ និង៩០

របាយការណ៍វាយតម្លៃផលនេសាទ ដែលចាប់បាននៅឆ្នាំ១៩៩៩ នៃគ្រោងការណ៍ស្រាវជ្រាវ សម្រាប់ការគ្រប់គ្រងការនេសាទទឹកសាបកម្ពុជា របស់គណៈកម្មការទន្លេមេគង្គបានប៉ាន់ស្មានថា ក្រុមត្រី ឆ្លាមឆ្មារ នៅប្រព័ន្ធទឹកសាបកម្ពុជាដែលរួមមានយ៉ាងហោចណាស់៥-៦ប្រភេទដូចជា ត្រីប្រាធំ ត្រីពោ ត្រចៀកខ្មៅ ត្រីប្រាខ្មៅ ត្រីកែ ត្រីឆ្វៀតធំ ត្រីបុងឡាវ ត្រីប្រាកណ្ដុរ ជាដើម បានរួមចំណែកនៅក្នុងផលនេសាទទឹកសាបកម្ពុជាសរុបប្រហែលចំនួន៣%ប៉ុណ្ណោះ។ដោយឡែកនៅមានព័ត៌មានដ៏គួរឲ្យចាប់អារម្មណ៍មួយទៀតគឺការនេសាទដោយឧបករណ៍ដាយត្រី ដែលធ្វើសកម្មភាពនៅតាមដងទន្លេសាប ត្រូវបានគេរាយការណ៍ថាពពួកត្រីប្រភេទនេះបានអវត្តមានទាំងស្រុងនៅឆ្នាំ១៩៩៩នេះ តែម្តងដែលធ្វើឲ្យអ្នកនេសាទដាយត្រីស្ទើរតែទាំងអស់មានការខកចិត្តយ៉ាងខ្លាំង ដោយទទួលបានផលចំណេញតិចតួច បំផុត។

គួបផ្សំនឹងព័ត៌មានចេញពីលទ្ធផលស្រាវជ្រាវខាងលើនេះការអង្កេតកត់ត្រាពីសមាសភាពត្រីប្រាធំនៅក្នុងផលនេសាទស្រស់ និងកែឆ្នៃដែលដឹកជញ្ជូនតាមផ្លូវគោក និងផ្លូវទឹក ចេញពីតំបន់នេសាទក្នុងបឹងទន្លេសាប និងតំបន់ដងទន្លេសាបមកលក់ចែកចាយនៅរាជធានីភ្នំពេញ ដែលអនុវត្តចាប់ពីឆ្នាំ១៩៨១ រហូតមកដល់ឆ្នាំ១៩៩៩ក៏បានបង្ហាញឲ្យឃើញពីនិន្នាកាថយចុះជាលំដាប់លំដោយរបស់ទំនិញត្រីប្រាធំស្រស់និងកែឆ្នៃដូចក្នុងតារាងលេខ៤ខាងក្រោម៖

*(នៅមានត)*

ដោយ ទូច ស៊ាងតាណា

## ១- ពន្យល់ពាក្យ

កសិណ ន. : ជាប្រភេទនៃសមថកម្មដ្ឋាន ដែលកំណត់យកពណ៌សំបុរជាអារម្មណ៍ ជាគ្រឿងដឹកមកកាន់ចិត្ត។ រូបតាងជាសំអាង : កសិណសាក្សី យើងនឹងយកពាក្យនេះជាកសិណមិនបានទេ។

កសិណនៃសមថកម្មដ្ឋានមាន ១០ប្រការ គឺ ៖

| | | |
|---|---|---|
| ១. បឋវិកសិណ | = | យកដីជាអារម្មណ៍ បើចម្រើនបានសម្រេចអាចនិម្មិត(កាឡា)ខ្លួនមួយឱ្យឃើញច្រើន អាចនិម្មិតឱ្យកើតជាផែនដីនៅកណ្តាលអាកាស ឬ លើទឹក រួចទៅឈរ អង្គុយ ដើរលេងលើនោះ |
| ២. អបោកសិណ | = | យកទឹកជាអារម្មណ៍ បើចម្រើនបានសម្រេច អាចនិម្មិតផែនដីឱ្យទៅជាទឹក អាចនិម្មិតជាភ្លៀង អាចញាំងភ្នំនិងផែនដីឱ្យកក្រើក |
| ៣. តេជោកសិណ | = | យកភ្លើងជាអារម្មណ៍ បើចម្រើនបានសម្រេច អាចនិម្មិតធ្វើភ្លើងឱ្យឆេះ ឬឱ្យរលត់អាចបង្កើតពន្លឺមើលឃើញរូបទាំងអស់ |
| ៤. វាយោកសិណ | = | យកខ្យល់ជាអារម្មណ៍ បើចម្រើនបានសម្រេច អាចនិម្មិតខ្យល់ |
| ៥. នីលកសិណ | = | យកពណ៌ខៀវជាអារម្មណ៍ បើចម្រើនបានសម្រេច អាចនិម្មិតងងឹត |
| ៦. បីតកសិណ | = | យកពណ៌លឿងជាអារម្មណ៍ បើចម្រើនបានសម្រេច អាចនិម្មិតអ្វីៗឱ្យទៅជាមាស |
| ៧. លោហិតកសិណ | = | យកពណ៌ក្រហមជាអារម្មណ៍ បើចម្រើនបានសម្រេច អាចនិម្មិតអ្វីៗឱ្យទៅជាក្រហម |
| ៨. ឱទាតកសិណ | = | យកពណ៌សជាអារម្មណ៍ បើចម្រើនបានសម្រេច អាចនិម្មិតអ្វីៗឱ្យទៅជាស អាចទប់ខ្លួនមិនឱ្យងងុយ អាចកំចាត់ងងឹត |
| ៩. អាលោកកសិណ | = | យកពន្លឺជាអារម្មណ៍ បើចម្រើនបានសម្រេច អាចធ្វើបានដូចឱទាតកសិណ |
| ១០. បរិច្ឆិន្នាកាសកសិណ | = | យកប្រហោងជាអារម្មណ៍ បើចម្រើនបានសម្រេច អាចដើរទម្លុះផែនដី ឬភ្នំ |

មគ្គុទ្ទេសក៍វប្បធម៌ទូទៅ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

# ២- ស្វែងយល់ពីប្រវត្តិសង្គមមនុស្ស

ផែនដីយើងកាលពីដើមជាដុំភ្លើងវិលជានិច្ច។យូរមកដោយការប្រែប្រួលនៃធាតុធម្មជាតិផ្សេងៗដុំភ្លើងនោះបានត្រជាក់ៗរុក្ខជាតិសត្វតូចធំចាប់ផ្ដើមមានជីវិតឡើង។តមកទៀតមនុស្សក៏បានកើតឡើងដែរ។តាំងពីមានមនុស្សមក គេឃើញមានសង្គមមនុស្សប្រាំ វិវត្តពីទាបទៅខ្ពស់ ជាលំដាប់៖

- សង្គមសមុហភាពបុព្វកាល
- សង្គមទាសភាព
- សង្គមសក្តិភូមិ
- សង្គមមូលធននិយម
- សង្គមសង្គមនិយម

១. សង្គមសមុហភាពបុព្វកាល :

ដើមឡើយមននុស្សរស់ដោយសារធម្មជាតិ ដើររបេះផ្លែឈើចិញ្ចឹមជីវិតហើយទៅណាមកណា ទាំងហ្វូងៗ ។ ក្នុងការតស៊ូទល់នឹងធម្មជាតិសម័យនោះ មនុស្សចេះសាមគ្គីស្រឡាញ់គ្នាជាពន់ពេក គំនិត ឆបោក ជិះជាន់គ្នាពុំទាន់កើតមាននៅឡើយ។

២.សង្គមទាសភាព :

ក្នុងការបង្កបង្កើនផល( ការងារ ) មនុស្សបានរកឃើញមធ្យោបាយជាច្រើន ហើយបានចេញ កាប់គាស់ចម្ការ ចិញ្ចឹមសត្វ ត្រួតត្រាលើធម្មជាតិបានខ្លះ ជាហេតុផ្ដើមការរកស៊ីរស់នៅប្លែកៗគ្នា មានខ្លះ ខ្លាំងពូកែ ដើរកំហែងអ្នកទន់ខ្សោយឱ្យរកប្រយោជន៍ឱ្យខ្លួន ។

ក្នុងសង្គមនេះគេឃើញ ៖

* ការបង្កបង្កើនផលិតកម្ម : ចេះចិញ្ចឹមសត្វ កាប់គាស់ដីនឹងកម្លាំងមនុស្សផ្ទាល់។ ផលិតកម្មនៅខ្សោយ។
* ទំនាក់ទំនងផលិតកម្ម : (មនុស្សនឹងមនុស្ស) បំណែងចែកផលិតផលមិនបានស្មើគ្នាទេ។ ខ្ញុំកំដរ ឬទាសាធ្វើការចិញ្ចឹមចៅហ្វាយម្ចាស់។ មានការជិះជាន់គ្នា: ទំនាស់វណ្ណៈរវាងខ្ញុំកំដរនឹងចៅហ្វាយ ម្ចាស់ ។

៣.សង្គមសក្តិភូមិ :

- ការបង្កបង្កើនផលិតកម្ម : ឧស្សាហកម្មគ្រួសារ ត្បាញក្ដួររាស់នឹងគី នង្គ័ល រនាស់ បាន ចម្រើនជាងសម័យទាសភាព។

- ទំនាក់ទំនងផលិតកម្ម : ស្ដេចត្រាញ់(សក្តិភូមិ) បង្ខំឱ្យអ្នកងារកសិករធ្វើការ ធ្វើស្រែឱ្យខ្លួន ។ មានទំនាស់វណ្ណៈទៀតរវាងសក្តិភូមិនឹងអ្នកងារ។

៤.សង្គមមូលធននិយម :

- បង្កបង្កើនផលិតកម្ម : ឧស្សាហកម្មធំៗ រោងចក្រ មនុស្សប្រើកម្លាំងម៉ាស៊ីនត្រួតធម្មជាតិ។

- ទំនាក់ទំនងផលិតកម្ម : នាយទុនប្រមូលយកផលតែម្នាក់ឯង ជិះជាន់កម្មករឱ្យរងទុក្ខវេទនា ។ មានទំនាស់វណ្ណៈរវាងនាយទុននឹងកម្មករ ។

៥.សង្គមសង្គមនិយម :

- ការបង្កបង្កើនផលិតកម្ម : ឧស្សាហកម្មធំៗ រោងចក្រ មនុស្សបង្កើតតិចនិកថ្មីៗ ត្រួតត្រាធម្មជាតិ ។

- ទំនាក់ទំនងផលិតកម្ម : បែងចែកឱ្យអ្នកមកធ្វើការទាំងអស់គ្នា ផ្អែកទៅលើគោលការណ៍ «ម្នាក់ៗត្រូវឱ្យទៅសង្គមតាមសមត្ថភាពរៀងៗខ្លួន ហើយសង្គមសងមកវិញ តាមការងារ រួចតាមសេចក្តី ត្រូវការនៃម្នាក់ៗ» ។ ការវិវត្តនៃសង្គមពីទាបទៅខ្ពស់នោះ បានជួបប្រទះនូវការថ្នាំងថ្នាក់ជាច្រើន ចៀស វាងការបដិវត្តមិនបាន។ ដូចជាបដិវត្តន៍ឆ្នាំ១៧៨៩ រំលាយរបបសក្តិភូមិនៅប្រទេសបារាំង បដិវត្តន៍ ខែតុលា១៩១៧ នៅប្រទេសរុស្ស៊ី ។ល។

អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ុំ ថុង

# VIII- នាទីកំណាព្យ

## ឃាតកឥតពូជ (ភាគគតិ)

«... មនុស្សធម៌បាត់បង់ ខ្លួនមនុស្សចិត្តសត្វ លែងស្គាល់
ប្អូនបង
ជាតិជាមួយគ្នា ប្រហារចាប់ចង ចិត្តពាលយង់ឃ្នង
មោហ៍បាំងជុំជិត ។
ងងឹតពុំយល់ លែងដឹងលែងស្គាល់ ពូជសាសន៍ញាតិមិត្ត
ស៊ូលះជាតិខ្លួន យកសួនគាប់ចិត្ត បម្រើគំនិត
នរណាក៏ខ្លាំង។
វាយតែជាតិខ្លួន ហើយស្រែកផ្ទួនៗ ថាខ្លួនវាយខ្លាំង
ឃើញសុទ្ធខ្មោចខ្មែរ នៅតែស្រវាំង ងងើលភ័ន្តភាំង
ថាខ្មែរអប្រិយ ។ ...»

មើលផែនដីខ្មែរ - ជួន ម៉ែន

## មេអំបៅនិងដង្កូវ (បទភាគគតិ)

« មេអំបៅថា អាចោរមោហា អាដង្កូវនេះ
រូបរាងអាក្រក់ ក្រខ្វក់អ្វីម្ល៉េះ ក្លិនខ្លួនឆ្អាបឆ្អេះ
អញខ្ពើមណាស់ណា ។
ទៅណាទៅខោល អាក្រាតនននល ជាអានាថា
ម្ដេចក៏គឃ្លើន ព្រហើនអស្ចារ្យ វារលេងលើផ្កា
ផ្កានេះបាត់ក្លិន ។
ចៀសចេញឱ្យឆាប់ ខំនៅនឹងស្លាប់ នឹងរិទ្ធភមរិន្ទ
ចិញ្ចឹមជីវិត នឹងផ្កាមានក្លិន ជាតិឯងជាតិហីន
ទៅស៊ីអាចម៍ទៅ។
ដង្កូវថាឃើ ពីម្សិលមិញតើ ភ្លេចភ្លាមហើយចៅ
ស្ទាបខ្លួនទៅមើល ត្រជាក់ឬក្ដៅ សត្វមេអំបៅ
ចេញទៅពីណា ។
ឱ្យដឹងជាតិខ្លួន សឹមលេងសំនួន ដៀលតិះតាមការ
កុំអាលត្មះអញ ជាមេជាបា ដូចពាក្យឧបមា
បាចខ្សាច់ប្រាសខ្យល់ ។ »

វិជ្ជាខេមរភាសា - ម៉ុក សំឱក

## ល្បើកទន្សាយ និង ខ្យង

ថ្ងៃមួយ មានទន្សាយមួយចុះទៅផឹកទឹកត្រពាំង ហៀបនឹងអោនក្បាលផឹកទៅហើយ ស្រាប់តែខ្យងស្រែកសួរថា៖

- បងទន្សាយមកផឹកទឹកមានសុំអ្នកណាទេ?
- ទន្សាយងើបមុខឡើងឃើញខ្យងក៏ឆ្លើយទាំងមួរម៉ៅថា ៖
- ត្រពាំងនេះគ្មានម្ចាស់ទេ យើងមិនចាំបាច់សុំអ្នកណាឡើយ។
- ខ្យងបាននិយាយបន្តថា ៖
- យើងថែរក្សាទឹកនេះយូរណាស់មកហើយ បើបងចង់ផឹកត្រូវសុំយើង។
- ទន្សាយពោលតបមកវិញថា ៖
- នែ៎! បងខ្យងយកមាត់ធ្វើជើងអួតឯងថែរក្សាទឹកនេះផង។
- ខ្យងស្រដីតបមកវិញថា ៖
- ខ្ញុំគ្មានជើងមែនពិតតែបើបងចង់ភ្នាល់រត់ប្រណាំងគ្នា ក៏ខ្ញុំមិនខ្លាចបងទន្សាយឯង ដែរ។
- ទន្សាយបានពោលបន្ថែមថា ៖
- ភ្នាល់ក៏ភ្នាល់! ខ្ញុំទៅខ្លាចអីបងខ្យងឯង ស្អែកព្រឹកយើងជួបគ្នានៅទីនេះ យើងរត់ប្រណាំងគ្នាបីជុំត្រពាំង។
- ថាហើយទន្សាយក៏ដើរចេញទៅ។ ចំណែកឯខ្យងក៏ហៅគ្នីគ្នាមកប្រជុំ ហើយមូលមាត់គ្នាថា ៖ យើងត្រូវវាយបណ្ដាក់គ្នាជុំវិញត្រពាំង ហើយបើទន្សាយស្រែកហៅ អ្នកនៅខាងមុខត្រូវឆ្លើយថា «កូក!»។

ស្អែកឡើង ទន្សាយមកដល់ឃើញខ្យងនៅចាំនៅនឹងកន្លែងដែលបានណាត់គ្នា ទន្សាយ និង ខ្យង ក៏ចាប់ផ្ដើមរត់ប្រណាំង។ លុះទន្សាយរត់បានមួយជុំត្រពាំង ក៏ស្រែកប្រកូកហៅខ្យងថា ៖

វ៉ឺយបងខ្យង! ខ្យងនៅខាងមុខទន្សាយឆ្លើយឡើងថា ៖ កូក!។

ទន្សាយឮសម្លេងខ្យងនៅពីមុខខ្លួនក៏ប្រឹងរត់ពេញទំហឹង។ លុះរត់បានមួយជុំទៀតក៏ស្រែកហៅខ្យងម្ដងទៀត។ ម្ដងនេះវាឮសូរសម្រែកខ្យងនៅពីមុខវាទៀត វាក៏ខំបន្ថែមល្បឿនអស់ពីក្នុងខ្លួន។ ទីបំផុត វារត់មកដល់ទីណាត់ ឃើញខ្យងនៅចាំវាទីនោះស្រេច។ ទន្សាយនឹកខ្មាស់ខ្លួនឯង រត់ចាញ់ខ្យងក៏គៀស ចេញពីទីនោះ ហើយប្ដេជ្ញាឈប់ផឹកទឹកត្រពាំងតាំងពីពេលនោះមក ។



ប្រាសាទកំពង់ព្រះ
ស្ថិតនៅក្នុងភូមិកំពង់ព្រះ ឃុំឆ្នុកទ្រូ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង



ប្រាសាទក្រវាន់
ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប